**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# សិទ្ធិជនជាប់ចោទនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **តាក់សុគន្ធា**
លោក **ត្រី ចាន់ណេត**

ណែនាំដោយ
លោក **រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **តាក់ សុគន្ធា** និងឈ្មោះ **គ្រី ចាន់ណេត** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២៣ ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌ចំពោះ**

លោកឪពុក **តាក់ វ៉ាឌុច** លោកឪពុក **ច្ឆាន ចាន់នី**

អ្នកម្តាយ **ឈិន វណ្ណធី** អ្នកម្តាយ **យ៉ង់ សុខគឿន**

ជាកិច្ចបឋមកូនៗ សូមឱនកាយថ្វាយបង្គំប្រណិបតន៍ និងសម្តែងនូវកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់ចំពោះ អ្នកមានគុណទាំងបួនដែលបានផ្តល់នូវកំណើតចិញ្ចឹមបីបាច់ថែរក្សាខិតខំលះបង់កម្លាំងកាយ និងកម្លាំងចិត្តព្រមទាំងសម្ភារៈសព្វបែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនៗទាំងអស់ដោយដៃផ្ទាល់ជាមួយ និងក្តីស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌ចាប់តាំងពីកំណើតរហូតដល់កូនបានធំពេញវ័យ និងថែមទាំងបានជួយឧបត្ថម្ភដល់កូនទទួលបានការអប់រំចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សាហើយ ពេលនេះរូបកូនទាំងពីរនាក់ក៏ជិតបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រក្នុងរយៈពេលដ៏ខ្លីខាងមុននេះ។ លទ្ធផលដែលទទួលបានកន្លងមកនិងរួមទាំងការជិតឈានដល់ការបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សាទាំងអស់នេះ គឺកើតចេញពីកម្លាំងញើសឈាមរបស់លោកអ្នកមានគុណទាំងបួនក្នុងការតស៊ូជម្នះនូវភាពលំបាក គ្រប់បែបយ៉ាងដើម្បីអោយកូនៗបានសម្រេចនូវក្តីស្រម៉ៃរបស់ខ្លួនទៅថ្ងៃអនាគត។

យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ** ទាំងអស់ដែលបង្រៀននៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយពន្យល់ និងផ្តល់ការអប់រំល្អៗ កាលពីឆ្នាំសិក្សាកន្លងទៅ។

ជាពិសេសយើងខ្ញុំក៏សូមថ្លែងអំណរគុណដ៏ឧត្តុងឧត្តមចំពោះលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះចំពោះប្រធានបទ **សិទ្ធិជនជាប់ចោទនៅកម្ពុជា** ដោយលោកសាស្ត្រាចារ្យបានចំណាយពេលដ៏មានតម្លៃដើម្បីជួយផ្តល់ជាគំនិតយោបល់ល្អៗ រហូតសម្រេច បានលទ្ធផលគួរជាទីពេញចិត្ត។

ជាចុងបញ្ចប់យើងខ្ញុំទាំងអស់គ្នាសូមប្រសិទ្ធិពរជ័យជូនមាតាបិតា លោកសាស្ត្រាចារ្យ សូមឱ្យមានសុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ដោយកាលពីឆ្នាំកន្លងទៅយើងខ្ញុំធ្លាប់បានសិក្សាអំពីសិទ្ធិ នានាដែលសាលាបានរៀបចំនិងបានសិក្សាអំពីច្បាប់នានាដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិមួយចំនួននិងយល់ឃើញថាសិទ្ធិមនុស្សគឺមានសារៈសំខាន់ណាស់មិនថាស្ថិតនៅទីណា ឬ ក្នុងដំណាក់ កាលណានោះទេ គឺត្រូវតែទទួលបានសិទ្ធិគ្រប់ពេលវេលាជាពិសេសគឺការអនុវត្តចំពោះជនជាប់ចោទ ក្នុងរយៈកាលចុងក្រោយនេះសង្កេតឃើញថាការអនុវត្តការការពារសិទ្ធិមនុស្ស និងសិទ្ធិជនជាប់ចោទនៅកម្ពុជា មួយចំនួនមានភាពល្អប្រសើរជាងមុន ប៉ុន្តែក្នុងនោះយើងឃើញថាចំណុចមួយចំនួនមិនទាន់គ្រប់ជ្រុងជ្រោយ នៅឡើយនោះទេពោល គឺមានភាពខ្វះចន្លោះមិនទាន់បានពេញលេញនោះទេ។ ហេតុដូចនេះយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសយកនូវប្រធានបទ **សិទ្ធិជនជាប់ចោទនៅកម្ពុជា** នេះមកស្រាវជ្រាវសរសេរ ចងក្រងជាសារណាបញ្ចប់ការសិក្សា។ សារណានេះគឺ មានគោលបំណងឱ្យអ្នកសិក្សាក៏ដូចជាពលរដ្ឋទាំងអស់បានស្វែងយល់អំពីសិទ្ធិរបស់ខ្លួនដែលមាននៅពេលជាប់ឃុំនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ និងដើម្បីជៀសវាងនូវការរំលោភបំពានសិទ្ធិពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចនិងស្ថាប័នតុលាការ ។

យើងខ្ញុំទាំងពីរនាក់សូមអភ័យទោសជាមុនចំពោះការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំដែល បានចងក្រងជាសារណានេះ ប្រាកដជាមានចំណុចខ្វះចន្លោះមិនទាន់គ្រប់គ្រាន់នៅត្រង់ចំណុចណាមួយជាមិនខានឡើយ ប៉ុន្តែក្រុមខ្ញុំរីករាយនិងទទួលយកការរិះគន់ដើម្បីស្ថាបនាពីសំណាក់អ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យមិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា នូវពាក្យពេចន៍ វគ្គឃ្លា វេយ្យាករណ៍ ទាំងផ្នែកខ្លឹមសារ អក្ខរាវិរុទ្ធ និងវិធីសាស្ត្រក្នុងការសរសេរ។

សូមអ្នកសិក្សាក៏ដូចជានិស្សិតមេត្តាអភ័យទោសនូវរាល់កំហុសឆ្គងរបស់យើងខ្ញុំទាំងពីរនាក់ និង សូមមិត្តនិស្សិតធ្វើការសិក្សាស្រាវជ្រាវបន្ថែមដើម្បីបំពេញចំណុចខ្វះខាតរបស់ពួកយើងខ្ញុំទាំងពីរនាក់ដើម្បីទុកជាឯកសារដល់អ្នកមិត្តនិស្សិតជំនាន់ក្រោយ។

# មាតិកា

សេចក្តីផ្តើម............................................................................................ ១

ជំពូកទី១៖ សិទ្ធិការពារខ្លួនមុនពេលជំនុំជម្រះ

១. សិទ្ធិជូនដំណឹងនៅពេលចាប់ខ្លួន................................................................ ៣

ក. សិទ្ធិទទួលដំណឹងពីបទចោទ................................................................ ៣

ខ. សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន................................................................ ៤

គ. សិទ្ធិបង្ហាញខ្លួនចំពោះចៅក្រម................................................................ ៤

១.២. សិទ្ធិការពារខ្លួននៅពេលចាប់ខ្លួន................................................................ ៤

ក. សិទ្ធិបង្ហាញតស្លូតាង................................................................ ៥

ខ. សិទ្ធិមិនត្រូវបានគេបង្ខំឱ្យឆ្លើយ ឬ សារភាពដាក់បន្ទុកមកលើខ្លួន.............................. ៥

គ. សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម................................................................ ៦

១.៣ សិទ្ធិទទួលជំនួយផ្នែកច្បាប់................................................................ ៧

ក. សិទ្ធិជ្រើសរើសមេធាវី................................................................១១

ខ. សិទ្ធិក្នុងការពិភាក្សាជាមួយមេធាវីជាសម្ងាត់................................................................១១

គ. សិទ្ធិសុំផ្លាស់ប្តូរមេធាវី................................................................១៣

១.៤ សិទ្ធិជូនដំណឹងក្នុងដំណាក់កាលឃុំខ្លួន................................................................១៣

ក.សិទ្ធិទទួលបានដំណឹងពីថ្ងៃជំនុំជម្រះ................................................................១៤

ខ.សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេលយូរ................................................................១៤

គ.សិទ្ធិសុំឱ្យនៅក្រៅឃុំបណ្តោះអាសន្ន................................................................១៥

ឃ.សិទ្ធិប្តឹងជំទាស់ចៅក្រម................................................................១៦

១.៥. សិទ្ធិប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ................................................................១៨

ជំពូកទី២៖ សិទ្ធិការពារខ្លួនក្នុងពេលសវនាការ

២.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

២.២ សិទ្ធិទទួលបានការជំនុំជម្រះដោយសាធារណៈ................................................................២២

២.៣ សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះ................................................................២៣

២.៤ សិទ្ធិមានអ្នកបកប្រែភាសា........................................................................២៤


## ជំពូកទី៣ ៖ សិទ្ធិជនជាប់ចោទក្រោយពេលសវនាការ

៣.១ បណ្ដឹងឧទ្ធរណ៍...........................................................................................២៥
៣.២ សិទ្ធិប្ដឹងឧទ្ធរណ៍...........................................................................................២៦
៣.៣ សិទ្ធិធ្វើបណ្ដឹងសាទុក្ខ.....................................................................................៣០
សេចក្ដីសន្និដ្ឋាន.........................................................................................៣៤
អនុសាសន៍.................................................................................................៣៦
ឯកសារយោង
ឧបសម្ពន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅលើសកលលោកយើងនេះពុំមាន ប្រទេសណាមួយដែលចង់ឱ្យប្រជាជនរបស់ខ្លួនមានទុក្ខលំបាក វេទនា និងបាត់បង់តម្លៃជាមនុស្សនោះទេ ទោះបីជាប្រទេសនោះប្រកាន់យករបបដឹកនាំតាមបែប លទ្ធិប្រជាធិបតេយ្យ កុំម្មុយនីស ឬសង្គមនិយមក៏ដោយ ។ ចំណែកឯប្រជាពលរដ្ឋវិញក៏ដូច្នោះដែរ គឺពួកគេចង់បាន ចង់ឃើញប្រទេស របស់ពួកគេមានការរីកចម្រើនជឿនលឿន ប្រជាជនរស់នៅប្រកបទៅដោយសេចក្តីសុខ សន្តិភាពមានជីវភាពធូរធារ និង ចេះគោរពសិទ្ធិគ្នាទៅវិញទៅមក ។ ហេតុនេះហើយបានជាថ្នាក់ដឹកនាំនៃប្រទេសមហាអំណាច និងប្រទេសជា ច្រើនផ្សេងទៀតបានរួបរួមគ្នាបង្កើតនូវអង្គការអន្តរជាតិនានាជាច្រើនមានដូចជា អង្គការតាមតំបន់តាមភូមិភាគ ជាពិសេសគឺអង្គការសហប្រជាជាតិ ដែលមានចំនួនសមាជិកច្រើនជាងគេទាំងអស់ ។ អង្គការសហប្រជាជាតិគឺបាន បង្កើតឡើងនៅឆ្នាំ ១៩៤៥មានគោលបំណងដើម្បីទប់ស្កាត់នូវសង្គ្រាមលោកកុំអោយកើតមានឡើងទៀត ។ក្នុងគោលបំណងដូចខាងលើនេះ បណ្តាប្រទេសទាំងឡាយដែលជាសមាជិរបស់អង្គការសហប្រជាជាតិបាន ខិតខំរួមគ្នាបង្កើតនូវសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សនៅ ថ្ងៃ ១០ធ្នូ ឆ្នាំ១៩៤៨ ហើយបានប្រកាសទូទាំងសកលលោកដោយបើកចំហរ ទោះបីប្រទេសនោះជាសមាជិកឬមិនមែនជាសមាជិករបស់អង្គការនេះក៏ដោយ (ក្នុងនោះប្រទេសកម្ពុជាយើងក៏ជាប្រទេសហត្ថលេខីសេចក្តីប្រកាសនេះផងដែរក៏អាចផ្តល់សច្ចាប័នទទួល យកមកអនុវត្តនៅក្នុងប្រទេសរបស់ខ្លួនបានដែរ)។ មិនតែប៉ុណ្ណោះ អង្គការសហប្រជាជាតិក៏បានបង្កើតនូវលិខិតតូបករណ៍អន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្សជាច្រើនទៀតដូចជា អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ អនុសញ្ញាអន្តរជាតិប្រឆាំងអំពើធ្វើទារុណកម្ម.....ជាដើម ។

នៅក្នុងលិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិទាំងអស់នោះ ប្រទេសកម្ពុជាយើងក៏បានផ្តល់សច្ចាប័នដោយ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) នៅក្នុងកំឡុងឆ្នាំ១៩៩២ហើយត្រូវដាក់បញ្ចូលនិងបានចែងទទួលស្គាល់យ៉ាង ទូលំទូលាយនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា៣១ (១) បានចែងថា: ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយណាទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ ) ។ ដោយសារលិខិតទាំងអស់នេះហើយ ដែលធ្វើឱ្យប្រទេសកម្ពុជាយើងបង្កើតបាននូវរដ្ឋធម្មនុញ្ញមួយប្រកបដោយលក្ខណៈប្រជាធិបតេយ្យពោល គឺងាកមកកាន់របបលទ្ធិប្រជាធិបតេយ្យ គោរពតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល គោរពច្បាប់ គោរពសិទ្ធិមនុស្សពោលគឺឃើញថាប្រទេសកម្ពុជាយើងមានការយកចិត្តទុកដាក់ដល់សិទ្ធិពលរដ្ឋ។ ពលរដ្ឋគឺត្រូវបានរាប់បញ្ចូលទាំងជនសង្ស័យ ឬជនជាប់ចោទព្រោះថាគេបានចាត់ទុកជនទាំងនេះជាជន គ្មានទោសកំហុសរហូតដល់មានសាលក្រម ឬ សាលដីកាជាស្ថាពរ ជន

ជាប់ចោទគឺមានការបាត់បង់នូវអ្វីសំខាន់ៗ ដូចជា ការបាត់បង់ការងារ ឃ្លាតឆ្ងាយពីក្រុមគ្រួសារ សេរីភាពក្នុងការដើរហើរជាដើម ។ ប៉ុន្តែនៅមានសិទ្ធិជាច្រើន ទៀតដែលនឹងត្រូវយកមកការពារខ្លួន នៅពេលចាប់ខ្លួន ពេលឃុំខ្លួន និងក្នុងពេលសវនាការដែលគេហៅថា សិទ្ធិជនជាប់ចោទ ។

ដើម្បីងាយស្រួលក្នុងការពិភាក្សាថាជនជាប់ចោទនេះមានសិទ្ធិអ្វីខ្លះនោះ យើងគប្បីត្រូវយល់នូវពាក្យសិទ្ធិជនជាប់ចោទជាមុនសិន ។ពាក្យ"សិទ្ធិ គឺជាការទាមទារអំណាចក្នុងការ ឬជាការប្រគល់អំណាចនូវអ្វីគ្រប់យ៉ាងដែលមនុស្សជឿថា គេត្រូវមាន និងគួរតែមាន រីឯពាក្យ ជនជាប់ចោទ គឺជាជនដែលត្រូវបានចោទប្រកាន់ជាផ្លូវការរួចហើយពីសំណាក់ព្រះរាជអាជ្ញា។ ដូច្នេះពាក្យ សិទ្ធិជនជាប់ចោទ" យើងអាចសរុបបានថា គឺជាសិទ្ធិរបស់ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ ដោយព្រះរាជអាជ្ញាដែលត្រូវតែមានដើម្បីយកមកទប់ទល់ ឬការពារខ្លួនមិនត្រឹមតែចំពោះមុខព្រះរាជអាជ្ញាប៉ុណ្ណោះទេ សិទ្ធិនេះក៏ត្រូវអនុវត្តចំពោះភ្នាក់ងារអនុវត្តច្បាប់ដទៃទៀតដូចជា នគរបាលយុត្តិធម៌ ចៅក្រមស៊ើបសួរ និង ចៅក្រមជំនុំជម្រះជាដើម ។

សិទ្ធិរបស់ជនជាប់ចោទគឺមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាល(UNTAC) ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧និងអនុសញ្ញាអន្តរជាតិជាច្រើនផងដែរ ។

នៅក្នុងសារណាដែលយើងខ្ញុំទាំងអស់គ្នាបានតាក់តែងឡើងទាក់ទងទៅនឹងសិទ្ធិជនជាប់ចោទនេះគឺមាន គោលដៅចង់អោយអ្នកអនុវត្តច្បាប់ទាំងអស់មានការគោរពសិទ្ធិរបស់ជនជាប់ចោទ និងឈានទៅរកការផ្តន្ទាទោស តាមច្បាប់តែប៉ុណ្ណោះ ពោលគឺយើងធ្វើការវិភាគទៅលើសិទ្ធិរបស់ជនជាប់ចោទ ថាតើត្រូវបានគេរំលោភបំពានដែរ ឬទេ? មិនមែនមានន័យថាយើងការពារទៅលើអំពើប្រព្រឹត្តរបស់ពួកគេឡើយ ។

ដូច្នេះយើងនឹងពិនិត្យទាំងអស់គ្នាថា នៅពេលក្លាយជាជនជាប់ចោទ តើពួកគេមានសិទ្ធិអ្វីខ្លះដែលនឹងត្រូវយកមកការពារខ្លួនទាំងក្នុងពេលចាប់ខ្លួន ពេលឃុំខ្លួន ក្នុងពេល និងក្រោយពេលសវនាការ? ដែលចំណុចទាំងអស់នេះយើងនឹងធ្វើការពិភាក្សាបកស្រាយតាមដំណាក់កាលនីមួយៗដូចខាងក្រោម :

# ជំពូកទី១ ៖ សិទ្ធិមុនពេលជំនុំជម្រះ

## ជំពូកទី១៖ សិទ្ធិការពារខ្លួនមុនពេលជំនុំជម្រះ

យើងបានដឹងស្រាប់ហើយថាជនជាប់ចោទគឺជាជនដែលច្បាប់សន្មតថាគ្មានទោស ពោលគឺជាមនុស្ស ត្រឹមត្រូវដរាបណាតុលាការរកឃើញថាមានទោសកំហុស ។ ស្ថិតនៅក្នុងដំណាក់កាលមុនពេលជំនុំជម្រះជនជាប់ចោទមិនអាចត្រូវបានគេរំលោភបំពានឡើយ ។ ក៏ប៉ុន្តែក្នុងពេលបច្ចុប្បន្នភ្នាក់ងារប៉ូលីសនៅពេលចាប់ខ្លួនជនដែលគេសង្ស័យថា គឺតែងតែប្រើសិទ្ធិអំណាចរបស់ខ្លួនដើម្បីគាបសង្កត់ទៅលើជននោះ ។ ទង្វើទាំងអស់នេះ គឺជាអំពើអមនុស្សធម៌ដែលធ្វើឱ្យប៉ះពាល់ទៅលើច្បាប់យ៉ាងធ្ងន់ធ្ងរ គឺសំដៅលើការប្រើទារុណកម្មអមនុស្សធម៌ដែលកើតចេញមកពីមន្ត្រីអនុវត្តច្បាប់នានា។

### ១. សិទ្ធិជនជាប់ចោទនៅពេលចាប់ខ្លួន

នៅក្នុងចំណុចនេះយើងនឹងបង្ហាញជូនពីសិទ្ធិរបស់ជនជាប់ចោទ ក្នុងពេលដែលត្រូវបានចាប់ខ្លួនដោយនគរបាល ។

ជាការពិតណាស់ការការពារសន្តិសុខ ក៏ដូចជារក្សាបាននូវស្ថេរភាពសង្គមវាជាតួនាទីដ៏សំខាន់របស់នគរបាល ជាក់ស្តែងដូចជាមានការខិតខំស្រាវជ្រាវ និងមានភាពសហការគ្នាទើបសម្រេចបានលទ្ធផលជាផ្លែផ្កាដោយបានចាប់ ខ្លួនជនសង្ស័យដែលបានប្រព្រឹត្តបទល្មើស ។ ក៏ប៉ុន្តែការចាប់ខ្លួនជនជាប់ចោទមិនត្រូវបានគេបង្ខំឱ្យធ្វើទារុណកម្ម ឬ ទណ្ឌកម្ម ឬ ប្រព្រឹត្តកម្មកាចសាហាវ អមនុស្សធម៌ និងបន្ថោកបន្ទាបបានឡើយ[1]។ មិនតែប៉ុណ្ណោះការចាប់ខ្លួនបុគ្គលណាម្នាក់ត្រូវ មានភស្តុតាងដើម្បីបញ្ជាក់បានថាជននោះ ជាអ្នកប្រព្រឹត្តបទល្មើស[2] ។ ទន្ទឹមនឹងនេះជនជាប់ចោទ ក៏នៅមានសិទ្ធិសំខាន់ៗ មួយចំនួនទៀតដូចខាងក្រោម ៖

#### ក. សិទ្ធិទទួលដំណឹងពីបទចោទ

គ្រប់ជនជាប់ចោទទាំងអស់ ត្រូវមានសិទ្ធិឱ្យគេប្រាប់អោយដឹងនៅពេលចាប់ខ្លួនអំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមៗអំពីការចោទប្រកាន់ [3]។ នគរបាលយុត្តិធម៌មានកាតព្វកិច្ច ត្រូវតែប្រាប់បទចោទដែលនាំឱ្យមានការចាប់ខ្លួននោះ សូម្បីតែចៅក្រមស៊ើបសួរ ពិនិត្យអត្តសញ្ញាណជនត្រូវចោទ និងប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះនៃបទល្មើសដែលបានកំណត់ដោយច្បាប់[4] ព្រោះថាសិទ្ធិនេះត្រូវអនុវត្តគ្រប់ដំណើរការនីតិវិធីព្រហ្មទណ្ឌជាពិសេសវាមានសារៈសំខាន់នៅក្នុងរង្វង់សវនាការ។ ម៉្យាង

---

[1] មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

[2] មាត្រា ៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

[3] មាត្រា ៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ

[4] មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ការដែលធ្វើដូចនេះគឺ ដើម្បីឱ្យជនជាប់ចោទអាចរៀបចំការពារក្តីរបស់ខ្លួន ដោយបានដឹងជាមុនអំពីបទចោទដែលនឹងត្រូវលើកយកមកចោទប្រកាន់ ក្នុងពេលសវនាការឱ្យបានពិតប្រាកដ ។

### ខ. សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន

ក្រោយពីការចាប់ខ្លួនរួចមកជនជាប់ចោទចាំបាច់ត្រូវដឹងថា ហេតុអ្វីបានជាមានការចាប់ខ្លួន ។ ដូច្នេះនគរបាលយុត្តិធម៌ត្រូវប្រាប់លម្អិតពីសាក្សី ឬ ភស្តុតាងនានាដែលបង្ករឱ្យមានបទល្មើសកើតឡើង ពីព្រោះគ្មានជនណាម្នាក់ ដែលត្រូវបានគេគាបសង្កត់នូវសិទ្ធិក្នុងការសាកសួរ ឬ ទទួលដំណឹងអំពីអង្គហេតុលម្អិតដែលនាំឱ្យមានការចាប់ខ្លួន[5] ។ ចំណែកឯច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិមាត្រា ៦៧(១) ចែងថា ក្នុងកំឡុងពេលវេលាមួយសមស្របមុនសវនាការ ជននោះត្រូវទទួលបាននូវរាល់សំណុំឯកសារស្តីពីការចោទប្រកាន់ដែលតំណាងអយ្យការមានបំណង នឹងនាំយកមកក្នុងពេលជំនុំជម្រះ ។

ដូច្នេះជនសង្ស័យ ឬជនជាប់ចោទមានសិទ្ធិគ្រប់បែបយ៉ាងក្នុងការទាមទារឱ្យគេប្រាប់ភ្លាមៗនូវមូលហេតុ និង ប្រភេទបទល្មើសដែលបានចោទប្រកាន់មកលើខ្លួន។

### គ. សិទ្ធិបង្ហាញខ្លួនចំពោះចៅក្រម

សិទ្ធិនេះក៏ត្រូវចាត់ទុកថាជាសិទ្ធិមួយដែលមានសារៈសំខាន់ផងដែរព្រោះថារាល់ជនសង្ស័យ ឬ ជនជាប់ចោទត្រូវបាននគរបាលយុត្តិធម៌ឃាត់ខ្លួនត្រឹមតែ ៤៨ម៉ោង ប៉ុណ្ណោះដើម្បីរៀបចំកសាងសំណុំរឿង ប៉ុន្តែថិរវេលានេះនឹងត្រូវបានបន្តប្រសិនបើស្ថានភាពផ្លូវក្នុងការដឹកជញ្ជូនឆ្ងាយ ឬ ជួបប្រទះ និងបញ្ហាផ្សេងៗ[6]។ បន្ទាប់ពីការចាប់ខ្លួនជនជាប់ចោទមាន សិទ្ធិក្នុងការទៅបង្ហាញខ្លួនឱ្យបានឆាប់រហ័ស ដើម្បីឱ្យតុលាការធ្វើកាសម្រេចជាងនេះទៅទៀតគឺ ជនជាប់ចោទអាចស្នើរទៅចៅក្រមដើម្បីសុំឱ្យនៅក្រៅឃុំបណ្តោះអាសន្នថែមទៀតផង។

## ១.២. សិទ្ធិការពារខ្លួននៅពេលចាប់ខ្លួន

សិទ្ធិនេះគឺជាសិទ្ធិរបស់ពលរដ្ឋម្នាក់ៗ ដែលរស់នៅក្នុងសង្គម ហើយត្រូវបានការពារដោយច្បាប់ជាតិ ( រដ្ឋធម្មនុញ្ញ ) និងលិខិតតូបករណ៍អន្តរជាតិដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣បានចែងថា "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"។ តាមរយៈអត្ថន័យចុងក្រោយនៃមាត្រានេះ បានផ្តល់សិទ្ធិឱ្យជនជាប់ចោទអាចលើកយកភស្តុតាង ឬសាក្សី

[5] មាត្រា ៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ

[6] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

ទាំងឡាយណាដែលមានប្រយោជន៍ក្នុងការដោះបន្ទុក ដើម្បីឱ្យរួចផុតពីការចោទប្រកាន់របស់ព្រះរាជអាជ្ញា មិនតែប៉ុណ្ណោះ ថែមទាំងមានសិទ្ធិក្នុងការស្វែងរកមេធាវី ដើម្បីធ្វើជាជំនួយការខាងផ្លូវច្បាប់ទៀតផង។ ជនជាប់ចោទមានសិទ្ធិបង្ហាញជូននូវភស្តុតាង និង ការបកស្រាយច្បាប់ដល់តុលាការក្នុងកិច្ចការពារខ្លួន ដោយខ្លួនឯង ឬ តាមរយៈជំនួយផ្នែកច្បាប់ តាមការជ្រើសរើសរបស់ជនជាប់ចោទនោះ[7] ។

សិទ្ធិក្នុងការការពារខ្លួនរាប់ បញ្ចូលទាំងសិទ្ធិ ទទួលដំណឹងពីបទចោទ សិទ្ធិពិនិត្យសំណុំរឿង សិទ្ធិទទួលជំនួយផ្លូវច្បាប់ និង សិទ្ធិហៅសួរដេញដោលសាក្សី ។

ដូច្នេះសិទ្ធិការពារខ្លួនវាជាសិទ្ធិមួយដែលមានប្រយោជន៍ និងមានសារៈសំខាន់បំផុត ពីព្រោះវាអាចជួយជនជាប់ចោទមានឱកាសច្រើនក្នុងការដែលនាំឱ្យរួចខ្លួនពីការចោទប្រកាន់ ដោយសារតែបានផ្ដល់លទ្ធភាពទូលំទូលាយ ក្នុងការបញ្ចេញនូវសមត្ថភាព ជាពិសេសការដោះស្រាយខាងផ្លូវច្បាប់ និង ទទួលបាននូវជំនួយការពារលើវិស័យច្បាប់ថែមទៀតផង ។

**ក. សិទ្ធិបង្ហាញភស្តុតាង**

នៅក្នុងដំណាក់កាលនេះគឺជា ដំណាក់កាលមួយដែលជនជាប់ចោទ ត្រូវលើកយកភស្តុតាងណាដែលអាចជួយដោះបន្ទុកឱ្យខ្លួនប្រឆាំងទៅ និងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ការបង្ហាញនេះជនជាប់ចោទអាចលើក យកមកបង្ហាញដោយខ្លួនឯងក៏បាន ឬតាមរយៈមេធាវី។ តែបើយើងគិតពីគោលការណ៍នៃ ការសន្មតជាមុនថាបានទោសនោះជនជាប់ចោទត្រូវបានចាត់ទុកថាជាមនុស្សឥតទោសរហូតដល់តុលាការ រកឃើញទោសកំហុស មានន័យថា បន្ទុកនៅក្នុងការបង្ហាញភស្តុតាងគឺជា ការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាដែលត្រូវបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ[8] ក្នុងការបង្ហាញនូវរាល់ធាតុផ្សំនីមួយៗនៃបទចោទឱ្យលើសពីវិមតិសង្ស័យ[9] ។

**ខ. សិទ្ធិមិនត្រូវបានគេបង្ខំឱ្យឆ្លើយ ឬ សារភាពដាក់បន្ទុកមកលើខ្លួន**

នៅក្នុងប្រទេសកម្ពុជារបស់យើង ចម្លើយសារភាពទាំងឡាយណាដែលបានមកពីការបង្ខិតបង្ខំ ឬ ប្រើនូវទារុណកម្មណាមួយមិនត្រូវចាត់ទុកជាបានការនោះទេ[10]។ ដោយសារជនគ្រប់រូបទាំងអស់ត្រូវបានសន្មតជាមុន

---

[7] មាត្រា ១៤កថាខណ្ឌទី៣(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[8] មាត្រា ៦៦(២) លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

[9] រដ្ឋធម្មនុញ្ញមាត្រា ៣៨(៦) ចែងថា "...វិមតិសង្ស័យត្រូវបានជាផលប្រយោជន៍ដល់ជនជាប់ចោទ..."

[10] រដ្ឋធម្មនុញ្ញមាត្រា ៣៨(៥) នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
( មាត្រា ៣២១នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ )

ថាគ្មានទោសរហូតដល់តុលាការរកឃើញថាមានទោស ដូចនេះគ្មានជនណាម្នាក់ត្រូវបានបង្ខំឱ្យផ្តល់ភស្តុតាងដែលផ្ទុយនឹងអ្វីដែលគេមិនបានប្រព្រឹត្តនោះឡើយឬក៏ជាមូលហេតុដែលនាំឱ្យមានការកាត់ទោសពួកគេវិញដែរ។

ឧទាហរណ៍ ៖ នៅក្នុងពេលបច្ចុប្បន្នប៉ូលីសតែងតែប្រើនូវទារុណកម្មយ៉ាងកាចសាហាវ ដូចជាមានករណីមួយនៅក្នុងពេលដែល ប៉ូលីសចាប់ចោរបានម្តងៗ គឺប្រើអំពើយង់ឃ្នងក្នុងការដាក់ទណ្ឌកម្មដោយរួមមាន ឆក់ខ្សែភ្លើង វាយដោយប្រើស្នាប់ដៃ ទាត់និងស្បែកជើងមុខក្រាស់...ជាដើម ។

ការប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំលើ រូបរាងកាយ ឬ ផ្លូវចិត្តក្តីពេលខ្លះយើងគិតថា ជាមធ្យោបាយឆាប់បំផុតក្នុងការស្វែងរកការពិត។ ក៏ប៉ុន្តែមនុស្សភាគច្រើននៅពេលដែលទទួលរងនូវការឈឺចាប់ ឬការវាយដំខ្លាំងៗណាមួយនោះគេប្រាកដជានឹងនិយាយអ្វីៗទាំងអស់ទោះបីការឆ្លើយខុស ឬត្រូវក៏ដោយពោលគឺធ្វើយ៉ាងម៉េចដើម្បីបញ្ឈប់ការភ័យខ្លាចទាំងនោះតែប៉ុណ្ណោះ ។ វិធីសាស្ត្រដែលមានប្រសិទ្ធិភាពបំផុតនៃការរកការពិតគឺតាមរយៈការប្រមូលភស្តុតាងឯករាជ្យដែលអាចបង្ហាញដោយគ្មានវិមតិសង្ស័យ ថាជនជាប់ចោទបានប្រព្រឹត្តបទល្មើស ។ ដោយសារតែដូច្នេះហើយទើបមានបណ្តាប្រទេសជាច្រើននៅលើសកលលោក បានធ្វើការហាមប្រាមមិនឱ្យប្រើប្រាស់ចម្លើយសារភាពដែលជនជាប់ចោទបានរៀបរាប់ប្រាប់ដល់នគរបាលយុត្តិធម៌ ធ្វើជាភស្តុតាងទាំងស្រុងនោះទេ ប៉ុន្តែមានតែក្នុងករណីដូចខាងក្រោមទើបជនជាប់ចោទអាចទទួលការកាត់ទោសដោយផ្អែកលើភស្តុតាងទាំងស្រុងបាន ។

ឧទាហរណ៍ ៖ ជនជាប់ចោទបានសារភាពប្រាប់នគរបាលថា គាត់បានបានប្លន់អ្នកលក់មាសដោយភ្ជង់កាំភ្លើង ហើយគាត់បានក្រវែងកាំភ្លើងនោះចោលទៅក្នុង ត្រពាំងមួយនៅតំបន់ដែលគ្មានម្ចាស់កាន់កាប់ ហើយគាត់បានលក់មាសដែលគាត់ប្លន់បាននៅកន្លែងមួយផ្សេងទៀត ។ ជនរងគ្រោះស្គាល់អត្តសញ្ញាណរបស់ជនជាប់ចោទនៅពេលរៀបមនុស្សឱ្យឈរជាជួរ ហើយបានចង្អុលចំអ្នកដែលជាចោរប្លន់មាសរបស់គាត់ ។ បន្ទាប់មកនគរបាលបាន ឆែកឆេរត្រពាំងហើយក៏ប្រទះឃើញកាំភ្លើងនោះ។ នគរបាលទៅកន្លែងមួយផ្សេងទៀត ក៏ឃើញមាសដែលចោរលួចបាន។ ឥឡូវនេះ នគរបាលមានភស្តុតាង ៣ យ៉ាងដែលស្របទៅនឹងការសារភាពរបស់ជនជាប់ចោទ ។

**គ. សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម**

សិទ្ធិនេះមានការទាក់ទងដោយផ្ទាល់ទៅដល់សន្តិសុខផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ពីព្រោះនគរបាលយុត្តិធម៌ មិនបានយល់ច្បាស់លាស់អំពីច្បាប់ ពោលគឺតែងចាត់ទុកជនជាប់ចោទថាមានទោស ដោយចូលចិត្តប្រើនូវទារុណកម្ម ដ៏កាចសាហាវក្នុងកំឡុងពេលឃុំខ្លួន ។

ការធ្វើឱ្យមានការឈឺចាប់ និង រងទុក្ខយ៉ាងខ្លាំងខាងផ្លូវកាយ និង ផ្លូវចិត្ត ដែលបង្ករឡើងដោយអាជ្ញាធរសាធារណៈ ដើម្បីយកចម្លើយសារភាព និង ដើម្បីហេតុផលផ្សេង ដែលឈរលើមូលដ្ឋាននៃការរើសអើង ការធ្វើទុកបុកម្នេញទាំងនេះ យើងចាត់ទុកថាជាការធ្វើទារុណកម្ម។

ដូច្នេះរាល់ទណ្ឌកម្មលើរូបរាងកាយ ទណ្ឌកម្មដោយដាក់គុកងងឹត និង ទណ្ឌកម្មទាំងឡាយណា ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប នាំឱ្យបាត់បង់តម្លៃជាមនុស្ស ត្រូវបានហាមឃាត់ជាដាច់ខាត[11] ។ សិទ្ធិនេះក៏ត្រូវបានការពារដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣មាត្រា៣៨បានចែងថា ការបង្ខិតបង្ខំ ការធ្វើជាបលើរូបរាងកាយ ឬ ប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬ ជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដៃដល់ អ្នកចូលរួមប្រព្រឹត្ត និង អ្នកសមគំនិត ត្រូវទទួលទោស។

លើសពីនេះទៅទៀតរាល់ជនជាប់ចោទនីមួយៗ ក៏មានសិទ្ធិស្នើរសុំដល់នគរបាលយុត្តិធម៌ ដើម្បីធានាឱ្យបាននូវរាល់សុវត្ថិភាពក្នុងពេលដែលខ្លួនជាប់ឃុំឃាំង ពីព្រោះដើម្បីការពារនូវរាល់បទល្មើសមួយចំនួនកើតឡើង ដូចជាការលួចសម្លាប់ជនជាប់ចោទក្នុងមន្ទីរឃុំឃាំងជាដើម ។

### ១.៣ សិទ្ធិទទួលជំនួយផ្នែកច្បាប់

ពាក្យថាជំនួយខាងផ្លូវច្បាប់នេះ " Legal Aid " ទើបចាប់ផ្តើមមានអត្ថិភាពនៅក្នុងប្រទេសកម្ពុជាយើងបន្ទាប់ពីវត្តមានរបស់ UNTAC ក្រោយឆ្នាំ១៩៩១ប៉ុណ្ណោះ។ ក្រោយពី UNTACបានបញ្ចប់បេសកកម្មនៅកម្ពុជាមកអង្គការផ្តល់សេវាកម្មផ្នែកច្បាប់ដល់ជនក្រីក្រជាច្រើនបានចាប់ផ្តើមបង្កើតឡើងដូចជា អង្គការគម្រោង អ្នកការពារក្តី អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា អង្គការខ្មែរអ្នកការពារក្តីជាដើម មកទល់បច្ចុប្បន្ននេះអង្គការមួយចំនួនក៏បានបញ្ចប់សកម្មភាពរបស់ខ្លួនទៅហើយ។ បន្ទាប់មកក៏មានជំនួយ (១) ពីមូលនិធិគណៈមេធាវីនៃព្រះរាជាណាចក្រ(គណៈមេធាវី)ដែលមានឈ្មោះថា"វិភាគទានគណៈមេធាវី" (២) រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ថវិកាជំនួយផ្នែកច្បាប់ជារៀងរាល់ឆ្នាំ (៣) វិស័យកជន អង្គការ ឬ រាជរដ្ឋាភិបាលបរទេស[12] ។

ជនណាដែលមិនមានមេធាវីមានសិទ្ធិទទួលបានមេធាវីម្នាក់ ដែលមានបទពិសោធន៍ និងសមត្ថភាពប្រហាក់ប្រហែលទៅនឹងចរិតនៃបទល្មើស ដែលចោទប្រកាន់មកលើខ្លួនក្នុងគ្រប់រឿងក្តីទាំងអស់ដែលផល

[11] មាត្រា ៨១ នៃច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឱ្យប្រើនៅថ្ងៃ២១ ខែធ្នូ ឆ្នាំ២០១១
មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ

[12] មាត្រា ២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី និង វិធានផ្ទៃក្នុងរបស់គណៈមេធាវី

ប្រយោជន៍យុត្តិធម៌តម្រូវយ៉ាងដូច្នេះដើម្បីអោយមេធាវីនោះផ្តល់ជំនាញផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាព ដោយគ្មានបង់ថ្លៃ ប្រសិនបើពួកគេមិនមានមធ្យោបាយគ្រប់គ្រាន់ចំណាយលើសេវាកម្មបែបនេះ[13] ។

ជំនួយផ្លូវច្បាប់គឺជាបទបញ្ញត្តិនៃសេវាកម្មផ្លូវច្បាប់ដោយ មិនយកកម្រៃបំរើដល់ជនទាំងឡាយណាដែលមិនមានលទ្ធភាពជួលមេធាវី។ ទិសដៅដ៏សំខាន់បំផុតនៃកម្មវិធីជំនួយផ្លូវច្បាប់របស់ប្រទេស គឺធានាឱ្យបានថាជនគ្រប់រូបទាំងអស់ ជាពិសេសជនទាំងឡាយណាដែលត្រូវបានគេចោទ អំពីបទល្មើសមានសិទ្ធិទទួលបានយុត្តិធម៌ស្មើៗ តាមរយៈជំនួយរបស់មេធាវី ។

ជំនួយខាងផ្លូវច្បាប់ផ្តោតសំខាន់ទៅលើ សិទ្ធិក្នុងការមានមេធាវី ដូច្នេះរដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ថវិការ សម្រាប់ជំនួយផ្នែកច្បាប់[14] ហើយជនរងគ្រោះមានសិទ្ធិ រកមេធាវីដោយគ្មានបង់ប្រាក់ឈ្នួល[15] ។ បន្ថែមពីលើនេះទៅទៀត មេធាវីត្រូវបានគេតែងតាំងដោយស្វ័យប្រវត្តិដោយតុលាការ ក្នុងកាលៈទេសៈមួយចំនួនដោយមិនគិតពីប្រាក់កម្រៃប្រសិនបើចាំបាច់ ។ ក្នុងការអនុវត្តន៍ជាក់ស្តែងអង្គការមិនមែនរដ្ឋាភិបាលពេលខ្លះអាចទៅពិនិត្យមើលមន្ទីរឃុំឃាំងដើម្បីស្វែងរកជំនួយផ្នែកច្បាប់សម្រាប់ប់ជនជាប់ចោទ ហើយពេលខ្លះបងប្អូនសាច់ញាតិរបស់ជនជាប់ចោទអាច ទាក់ទងជាមួយអង្គការទាំងនេះដើម្បីស្នើរសុំជំនួយថែមទៀតផង ។

មេធាវីនឹងអាចត្រូវបានផ្តល់ជូនជនជាប់ចោទតាមរបៀប២យ៉ាងដូចខាងក្រោម :

**-តាមការស្នើរសុំ ៖** ក្នុងពេលដែលត្រូវជាប់ឃុំឃាំង ជនជាប់ចោទគ្រប់រូបមានសិទ្ធិក្នុងការស្នើរសុំទៅចៅក្រមដើម្បីរកមេធាវីមកការពារ ក៏ប៉ុន្តែក្នុងករណីជនជាប់ចោទស្នើរសុំ ប៉ុន្តែគ្មានលទ្ធភាពជួលមេធាវីបានចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចជួយ ជនជាប់ចោទក្នុងការរកមេធាវីដែលនឹងការពារជនជាប់ចោទ ដោយមិនយកកម្រៃ ។ **ឧទាហរណ៍៖** តាមសំណើររបស់ជនជាប់ចោទ ចៅក្រមអាចទាក់ទងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឱ្យផ្តល់មេធាវីសំរាប់ជនជាប់ចោទដោយមិនយកកម្រៃ ឬ ក៏ផ្តល់លេខទូរស័ព្ទ និង បញ្ជីឈ្មោះមេធាវីដែលអាចការពារបាន។

**-តាមការចាត់តាំងដោយតុលាការ ៖** យោងតាមមាត្រា៣០១នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧បានចែងថា : ការចាត់តាំងដោយឯកឯងនូវមេធាវីត្រូវធ្វើឡើងដោយប្រធានតុលាការ ក្នុងករណីដូចតទៅ :

[13] គោលការណ៍មូលដ្ឋានស្តីពីតួនាទីមេធាវីមាត្រា ៦ ការការពារពិសេសក្នុងរឿងក្តីយុត្តិធម៌ព្រហ្មទណ្ឌ (មាត្រា៥២ នៃក្រមសីលធម៌មេធាវី)

[14] គោលការណ៍មូលដ្ឋានស្តីពីតួនាទីមេធាវីមាត្រា ៣ ចែងថា "រដ្ឋាភិបាល និងធានាឱ្យមានថវិការគ្រប់គ្រាន់ និងប្រភពផ្សេងទៀត សម្រាប់សេវាផ្នែកច្បាប់ជួយដល់ជនក្រីក្រ និងចាំបាច់សម្រាប់ប់ជនដែលងាយនឹងរងគ្រោះ"

[15] មាត្រា ១៤ (៣.ឃ)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

- ជនជាប់ចោទជាអនីតិជនគ្មានទីពឹង

- ជនជាប់ចោទត្រូវជាប់ពីបទឧក្រិដ្ឋណាមួយ ហើយខ្លួនគ្មានលទ្ធភាពអាចពឹងអ្នកជួយការពារខ្លួន

- ជនជាប់ចោទជាមនុស្ស គ ថ្លង់ ខ្វាក់ ឬ ជនមានវិបត្តិស្មារតី

តាមរយ ៖ អត្ថន័យនៃមាត្រានេះហាក់ដូចជាបញ្ជូនសមត្ថកិច្ចទៅ ប្រធានតុលាការហើយដែលផ្តល់អំណាច ឱ្យចៅក្រមស៊ើបសួរក្នុងការសម្រេចថាតើវាចូលក្នុងករណីខាងលើដែរឬទេ។ ម៉្យាងវិញទៀតសិទ្ធិទទួលជំនួយផ្នែកច្បាប់ក៏ដូចជាសិទ្ធិមានមេធាវីដែរគឺ វាមានដំណាក់កាលរបស់វាដែលនឹងត្រូវយកមកអនុវត្តដូចខាងក្រោម :

➢ **នៅពេលចាប់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌**

ការចាប់ខ្លួនជនណាម្នាក់ត្រូវធ្វើឡើងស្របតាមបទបញ្ញាត្តិច្បាប់។ សិទ្ធិអំណាចក្នុងការចាប់ខ្លួនវាគឺ ជាតួនាទីរបស់នគរបាលយុត្តិធម៌ ក៏ប៉ុន្តែបើទោះបីជាស្ថិតនៅក្នុងស្ថានភាពមួយដែល ការចាប់ខ្លួននោះធ្វើឡើងដោយមានដីកា ឬ គ្មានដីកា (បទល្មើសជាក់ស្តែង ) ក៏ដោយ ជនជាប់ចោទនៅតែទទួលដំណឹងពីមូលហេតុនៃការចាប់ខ្លួនជាពិសេសទៅទៀតនោះ គឺប្រាប់ពីសិទ្ធិមានមេធាវីភ្លាមហើយនៅគ្រប់ករណីទាំងអស់មេធាវីការពារជនសង្ស័យ ឬ ជនជាប់ចោទនោះត្រូវទទួលបានសំណុំរឿងទាក់ទង និងការចោទប្រកាន់យ៉ាងយូរបំផុតក្នុងរយៈពេល៤៨ម៉ោងក្រោយពីការចាប់ខ្លួន[16] ។

ដូច្នេះនៅក្នុងដំណាក់កាលនេះមានសារៈសំខាន់ចំពោះជនជាប់ចោទ ដោយហេតុថាវាអាចធានាការពារនូវជនជាប់ចោទ ទាំងអស់ឱ្យរួចផុតពីការធ្វើបាបរបស់នគរបាលយុត្តិធម៌ ដែលជាទូទៅក្នុងការអនុវត្តន៍ភាគច្រើនសិទ្ធិនេះតែងទទួលរងនូវការរំលោភបំពាន ។

➢ **នៅពេលឃុំខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌**

ក្នុងរយៈពេលឃុំខ្លួន៤៨ម៉ោង ដោយនគរបាលយុត្តិធម៌គឺជាថេរៈវេលាមួយដ៏សំខាន់ ក្នុងការដែលត្រូវទទួលបានជំនួយផ្នែកច្បាប់ ជាពិសេសគឺសិទ្ធិមានមេធាវីតែម្តង។ សិទ្ធិពឹងពាក់មេធាវីត្រូវធានាជូនជាចាំបាច់នៅពេលដែលជនចោទជាប់ជាអនីតិជនឬការចោទប្រកាន់ពីបទឧក្រិដ្ឋត្រូវបានលើកឡើង[17]។ មេធាវីគឺជាមនុស្សម្នាក់ដែលមានការយល់ដឹងច្បាស់ពីវិស័យច្បាប់ យ៉ាងស្ទាត់ជំនាញ ដូច្នេះខណៈពេលដែលមេធាវីអាចជួបជនជាប់ចោទ ក៏ជាផ្នែកមួយក្នុងការជំនួយផ្នែកស្មារតីថែមទាំងអាចជួយជនជាប់ចោទឱ្យ រួចផុតពីការរំលោភបំពាន

[16] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[17] មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

ដោយនគរបាលព្រោះថា កាលដែលមានមេធាវីការពារ នគរបាលមិនអាចរំលោភសិទ្ធិជនជាប់ចោទបានទេ ដោយបារម្ភខ្លាចមានការប្តឹងប្តល់ទាក់ទងទៅ និងការរំលោភសិទ្ធិនេះពីសំណាក់មេធាវី ។

➢ **សិទ្ធិឆ្លើយសំណួររបស់ចៅក្រមដោយមិនចាំបាច់មានជំនួយពីមេធាវី**

ចៅក្រមស៊ើបសួរអាចសួរចម្លើយជនជាប់ចោទដោយគ្មានវត្តមានពីមេធាវី ប្រសិនបើជនជាប់ចោទបោះបង់ចោលយ៉ាងដាក់លាក់នូវវត្តមានរបស់មេធាវី និងអាចឆ្លើយនូវរាល់សំនួរទាំងឡាយណារបស់ចៅក្រមស៊ើបសួរដែលមិនអាចដាក់បន្ទុកមកលើខ្លួន[18]។ តែទង្វើទាំងអស់នេះវាអាចនាំឱ្យមានកង្វះខាត ឬផលមិនល្អចំពោះជនជាប់ចោទ ព្រោះជនជាប់ចោទភាគច្រើន គ្មានជំនាញយល់ដឹងផ្នែកច្បាប់ជ្រៅជ្រះនោះទេ ជាហេតុនាំឱ្យការឆ្លើយនូវរាល់សំណួរទាំងអស់នោះជះឥទ្ធិពលមិនល្អមក លើខ្លួនឯងដោយប្រការណាមួយ ។

ដូច្នេះការណែនាំជនជាប់ចោទដោយ អ្នកជំនាញផ្នែកច្បាប់ មានផលប្រយោជន៍សំខាន់ពាក់ព័ន្ធដល់ជនជាប់ចោទព្រោះអាចជាវិធានការមួយដែលមានផលជាវិជ្ជមាន ជាពិសេសចំពោះជនជាប់ចោទណាដែលមិនមានជំនាញ ឬ មិនដឹងពីភាពស្មុកស្មាញអំពីដំណើរការក្តីព្រហ្មទណ្ឌ ។

➢ **សិទ្ធិមិនឆ្លើយទៅនឹងសំណួររបស់ចៅក្រមប្រសិនបើមិនមានជំនួយពីមេធាវី**

មុនពេលសួរចម្លើយជនជាប់ចោទណាម្នាក់ ចៅក្រមស៊ើបសួរត្រូវប្រាប់អំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់ឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់។ចៅក្រមស៊ើបសួរប្រាប់ជនចោទជាប់ថា ខ្លួនអាចឆ្លើយនិងមិនឆ្លើយដោយសេរី ។ ប៉ុន្តែ ប្រសិនបើជនចោទជាប់ចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរត្រូវប្រាប់អំពីសិទ្ធិក្នុងការរកជំនួយមេធាវីមកជួយការពារខ្លួន ឬក្នុងការសុំចាត់តាំងមេធាវីឱ្យខ្លួនដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[19]។ ប៉ុន្តែប្រសិនបើជនចោទជាប់ចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរត្រូវប្រាប់អំពីសិទ្ធិក្នុងការរកជំនួយមេធាវីមកជួយការពារខ្លួន ឬក្នុងការសុំចាត់តាំងមេធាវីអោយខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បន្ថែមពីលើនេះទៅទៀត ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិននិយាយអ្វីទាំងអស់ទោះជាមាន ឬ មិនមានវត្តមានមេធាវីក៏ដោយ ។ គ្មានជនសង្ស័យ ឬជនជាប់ចោទណាម្នាក់ ត្រូវបានគេចាប់បង្ខំ ទាំងផ្លូវកាយ និងផ្លូវចិត្តអោយឆ្លើយសារភាពដាក់កំហុសលើខ្លួនឯង ឬ បង្ខំឱ្យឆ្លើយសារភាពទទួលកំហុសឡើយ[20] ។

---

[18] មាត្រា ១៤៥ វាក្យខណ្ឌ ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[19] មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[20] មាត្រា ៣៨ (៤ ) រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣,មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧, មាត្រា ១៤ កថាខណ្ឌទី៣ (ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។

ជនជាប់ចោទគ្មានកាតព្វកិច្ចតាមផ្លូវច្បាប់ណាមួយ ដើម្បីឆ្លើយនូវរាល់សំនួរនោះទេ ។ បន្ថែមពីនេះទៅទៀតក៏គ្មានបទល្មើសព្រហ្មទណ្ឌណាមួយចំពោះការខកខានមិនព្រមឆ្លើយនេះដែរ។ ដូច្នេះជនជាប់ចោទអាចនៅស្ងៀមដោយមិនឆ្លើយនូវរាល់សំណួរអ្វីទាំងអស់ ។ ប៉ុន្តែប្រសិនក្នុងករណីបើមេធាវីមិនបង្ហាញខ្លួនតាមកាលបរិច្ឆេទនិងពេលវេលាដែលបានកំណត់ទេទោះចៅក្រមមានសិទ្ធិសួរចម្លើយ ជនជាប់ចោទដោយមិនចាំបាច់មានវត្តមានមេធាវី និទ្ទេសស្តីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនចោទជាប់[21] ។

**ក. សិទ្ធិជ្រើសរើសមេធាវី**

ជាការពិតណាស់សិទ្ធិជ្រើសរើសមេធាវី អាចឱ្យជំបូន្មាន ជាពិសេសចំពោះនរណាម្នាក់ដែលត្រូវបានគេចោទប្រកាន់ពី បទល្មើសព្រហ្មទណ្ឌណាមួយ យ៉ាងហោចណាស់គេអាចស្គាល់មេធាវីដែលមាន បទពិសោធន៍ និង ជាអ្នកទទួលខុសត្រូវម្នាក់ ដែលគេត្រូវការពារក្នុងរឿងក្តីរបស់ខ្លួន។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬ អង្គការក្រៅរដ្ឋាភិបាល ដែលមានជំនាញពិសេសក្នុងការ ការពារក្តី ចំពោះកិច្ចការដ៏សំខាន់នេះមិនត្រូវទុករហូតដល់ក្រោយពេលចាប់ខ្លួននោះទេ ។ យកល្អត្រូវពិគ្រោះជាមួយមេធាវីអោយបានឆាប់រហ័ស ក្រោយពេលជនសង្ស័យដឹងថាខ្លួន កំពុងស្ថិតនៅក្រោមការតាមដាន ឬ ស៊ើបអង្កេត ។

នៅពេលជនជាប់ចោទ ត្រូវបានគេនាំយកមកចំពោះចៅក្រមស៊ើបសួរហើយមិនមានមេធាវី ជនជាប់ចោទមានសិទ្ធិជ្រើសរើសមេធាវីណាម្នាក់សម្រាប់ការពារខ្លួន។ ដោយហេតុថា ជនជាប់ចោទស្ថិតនៅក្រោមការឃុំគ្រងរបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចជួយជនជាប់ចោទក្នុងការ ផ្តល់ពត៌មានទាក់ទង និងការជ្រើសរើសមេធាវី ។ បើពុំដូច្នេះទេ ជនជាប់ចោទមិនអាចប្រើសិទ្ធិនេះបានទេ។ ដោយមានជម្រើសចៅក្រមស៊ើបសួរ អាចធ្វើការទាក់ទងមេធាវីណាម្នាក់ ឬ ស្នើសុំទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាត់តាំងមេធាវីម្នាក់ឱ្យមកការពារ។ បន្ទាប់មកទៀតចៅក្រមស៊ើបសួរត្រូវពន្យាការសួរចម្លើយរបស់ខ្លួន រហូតមេធាវីមកដល់ ។

**ខ. សិទ្ធិក្នុងការពិភាក្សាជាមួយមេធាវីជាសម្ងាត់**

ចាប់តាំងពីបានទទួលការចាត់តាំងមក មេធាវីមានសិទ្ធិពេញលេញក្នុងការទំនាក់ទំនងជាមួយកូនក្តីដោយសេរីទាំងនៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួននិង ទទួលបានពត៌មានពីតុលាការ ធ្វើការទាក់ទងក្នុងសំណុំរឿងរបស់កូនក្តី រួមទាំងសិទ្ធិក្នុងការថតចម្លងរាល់ឯកសារទាំងឡាយ ទាំងនេះដោយផ្អែកលើច្បាប់ស្តីពី

[21] មាត្រា ១៤៥វាក្យខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា : ប្រសិនបើមេធាវី ឬ អ្នកការពារសិទ្ធិមិនបានចូលខ្លួនមកតាមថ្ងៃនិងម៉ោងដូចបាន ណាត់នោះទេ ចៅក្រមស៊ើបសួបមានសិទ្ធិសួរចម្លើយដោយមិនចាំបាច់មានវត្តមាននៃមេធាវី ចៅក្រមស៊ើបសួរត្រូវកត់ជានិទ្ទេសអំពីអវត្តមាននេះក្នុងកំណាត់ហេតុសួរចម្លើយ ។

នីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា៣១៩ បានចែងថា : សំណុំរឿងត្រូវទុកឱ្យមេធាវី ឬ តំណាងស្របច្បាប់ពិនិត្យមើលបានគ្រប់ពេលវេលា ។ ការជូនសំណុំរឿងឱ្យមើលនេះ ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ឬថ្ងៃនៅក្នុងបន្ទប់ចៅក្រមស៊ើបសួរ បើទីកន្លែងនោះអាចទទួលឱ្យធ្វើបាន ។

មេធាវី ឬតំណាងស្របច្បាប់របស់ជនចោទជាប់ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរឱ្យប្រើលេខាធិការរបស់ខ្លួនឱ្យមកថតចម្លងឯកសារទាំងអស់ ដែលមាននៅក្នុងសំណុំរឿងក្រោមការទទួលខុសត្រូវរបស់ខ្លួនទាំងស្រុង ។ ប្រសិនបើចៅក្រមសម្រេចថា ចាំបាច់ត្រូវស៊ើបសួរទៀតតាមលំដាប់លំដោយនៃការស៊ើបសួរនេះ ទីប្រឹក្សារបស់ជនជាប់ចោទ ត្រូវតែបានទទួលដំណឹងជាបន្ទាន់ អំពីភស្តុតាងថ្មីៗបន្ថែម ឬស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរណាមួយដែលភាគីយល់ថាមានប្រយោជន៍សម្រាប់រឿងក្តីរបស់ខ្លួន។មេធាវីមានសិទ្ធិទទួលសំណុំរឿងអ្នកជាប់ចោទដោយគ្រាន់តែស្នើសុំជាលាយលក្ខណ៍អក្សរ នៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយអាចទទួលបានពីចៅក្រមនៅគ្រប់លទ្ធផលដែល បានមកពីការស៊ើបអង្កេតអំពីសេចក្តីរាយការណ៍របស់អ្នកជំនាញការដែលខ្លួនយល់ថាមានប្រយោជន៍ក្នុងការ ការពារកូនក្តីរបស់ខ្លួន។

ក្រៅពីនេះនៅក្នុងគោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី គោលការណ៍ ២១ ចែងថា : វាគឺជាភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការធានាដល់ មេធាវីនូវសិទ្ធិទទួលពត៌មានសមស្រប សំណុំរឿង និងឯកសារទាំងឡាយ តាមពេលវេលាមួយកំណត់ត្រឹមត្រូវ ដើម្បីផ្តល់នូវជំនួយសមស្របដល់កូនក្តីរបស់គេ ។ សិទ្ធិទាំងនេះ ត្រូវប្រគល់ពេលវេលាមួយអោយបានឆាប់រហ័សបំផុត។ ដោយសារតែមេធាវីដើរតួយ៉ាងសំខាន់ក្នុងដំណើរការផ្តល់យុត្តិធម៌ដ៏ត្រឹមត្រូវជាការសំខាន់ណាស់ដែលពួកគេត្រូវបានអនុញ្ញាតិ ឱ្យធ្វើតាមមុខងាររបស់ពួកគេដោយគ្មានការដាក់កំណត់តឹងតែង ឬ ជ្រៀតជ្រែក។ ដូច្នេះប្រសិនបើកូនក្តីកំពុងជាប់ឃុំ មេធាវីអាចទៅសួរសុខទុក្ខកូនក្តីរបស់ខ្លួនក្នុងពន្ធនាគារ និងប្រាប់ដល់កូនក្តីនៅរាល់ឯកសារទាំងអស់ដែលខ្លួនបានឃើញ ឬបានថតចម្លងពីសំណុំរឿង ដែលមេធាវីនោះយល់ថា មានសារៈប្រយោជន៍ក្នុងពេលការពារកូនក្តី[22] ។ កិច្ចសន្ទនារវាងភាគីនិងកូនក្តីនេះមិនត្រូវមាន គេលួចស្តាប់ ឬ ថតចម្លងទេ។ មេធាវីមិនត្រូវបានអនុញ្ញាតឱ្យប្រគល់ជូននូវឯកសារ ឬឧបករណ៍អ្វីដល់កូនក្តី របស់ខ្លួនដោយគ្មានការអនុញ្ញាតពិសេសពីចៅក្រមស៊ើបសួរនោះទេ។ មេធាវី ឬអ្នកតំណាងអាចឱ្យកូនក្តីរបស់ខ្លួនស្តាប់នូវរាល់ឯកសារទាំងឡាយដែលខ្លួនបានយល់ឃើញ ឬបានកត់ចេញពីសំណុំរឿង ហើយដែលខ្លួនបានយល់ឃើញថា មានប្រយោជន៍ក្នុងកិច្ចការពារកូនក្តីរបស់ខ្លួននោះ ។ ប៉ុន្តែមេធាវី

[22] មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា : ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនហើយជននោះមានមេធាវី ឬ អ្នកការពារសិទ្ធិអាចប្រាស្រ័យទាក់ទងបានដោយសេរីជាមួយកូនក្តីរបស់ខ្លួន ។

មិនត្រូវប្រគល់ឯកសារ ឬវត្ថុដល់កូនក្តីខ្លួនឡើយ កាលបើគ្មានការអនុញ្ញាតពិសេសពីចៅក្រមស៊ើបសួរ ។ ប៉ុន្តែ ជនជាប់ចោទអាចរៀបចំនិងផ្តល់នូវឯកសារផ្សេងៗដល់មេធាវីសម្រាប់ការពារខ្លួន ។

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ហើយចៅក្រមស៊ើបសួរជូនព័ត៌មាន នេះដល់ ព្រះរាជអាជ្ញា ជនចោទជាប់និង មេធាវី ហើយពីរថ្ងៃក្រោយចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យ ព្រះរាជ្ញាពិនិត្យ[23] ។ មេធាវីដែលការពារជនចាប់ចោទ ត្រូវទទួលការជូនដំណឹងអំពីកាលបរិច្ឆេទសវនាការឱ្យបាន យ៉ាងហោចណាស់ ១៥ថ្ងៃ មុនសវនាការ[24] ។

**គ. សិទ្ធិសុំផ្លាស់ប្តូរមេធាវី**

មេធាវីគឺជាមនុស្សម្នាក់ដែលត្រូវបានគេដឹងថា មានទេពកោសល្យក្នុងការការពារក្តី ទោះបីជារឿងនោះ ជារឿងព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីក៏ដោយ ។ ជាទូទៅ នៅពេលដែលជនណាម្នាក់ត្រូវបានជាប់ចោទថាបានប្រព្រឹត្ត បទល្មើសអ្វីមួយ ខ្លួនរមែងតែងតែចង់ទទួលបាននូវ មេធាវីដែលមានបទពិសោធន៍ច្រើនក្នុងការការពារក្តី ដើម្បី ជួយឱ្យខ្លួនរួចផុតពីការចោទប្រកាន់។ ប៉ុន្តែកាលបើ មេធាវីនោះគ្មានសមត្ថភាព ពោលគឺពុំសូវ មានជំនាញក្នុងការ ការពារក្តី ជាហេតុធ្វើអោយជនជាប់ចោទដែលជាកូនក្តីរបស់ខ្លួនប្រាកដជាត្រូវទទួលទោស ។ ដូច្នេះ ជនជាប់ ចោទគ្រប់រូបមានសិទ្ធិស្នើរសុំផ្លាស់ប្តូរមេធាវីតាមរយៈតុលាការប្រសិនបើខ្លួនយល់ថា មេធាវីដែលកំពុងការពារ ខ្លួននោះ មិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីការពារខ្លួនឱ្យបានល្អនោះទេ។ ចំពោះមេធាវីដែលកូនក្តី របស់ខ្លួន បានជ្រើសរើសសម្រាប់ការពារថ្មីនេះ ត្រូវធ្វើការទំនាក់ទំនងជាមួយមេធាវីចាស់ ក្នុងគោលដៅដើម្បីស្វែងយល់ឱ្យ កាន់តច្បាស់អំពីសំណុំរឿងទាំងឡាយដែល ជាប់ពាក់ព័ន្ធទៅនឹងកូនក្តីខ្លួន ដើម្បីចាប់ផ្តើមនីតិវិធីការពារជាថ្មីបន្ត ទៀត ។

### ១.៤. សិទ្ធិជនជាប់ចោទក្នុងដំណាក់កាលឃុំខ្លួន

នៅក្នុងដំណាក់កាលនៃការឃុំខ្លួននេះជនជាប់ចោទគឺ មានសិទ្ធិដូចពលរដ្ឋធម្មតាដែរ(តាមគោល ការណ៍សន្មតទុកជាមុនថាគ្មានទោស ) ប៉ុន្តែត្រូវគោរពទៅតាមបទបញ្ជាផ្ទៃក្នុងនៃពន្ធនាគារ ដែលត្រូវបានគេផ្តល់ ឱ្យនៅពេលដែលចូលមកដល់ ។ ករណីនេះក៏ត្រូវបានគេផ្តល់ឱកាសឱ្យធ្វើការប្តឹងតវ៉ាតាម ផ្លូវច្បាប់លើបុគ្គលណា មួយបានផងដែរ។

---

[23] មាត្រា ២៤៦ (១) នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា : កាលណាចៅក្រមស៊ើបសួរយល់ថា ការប្រមូលពត៌មានរបស់ខ្លួនចប់ហើយសំណុំ រឿងត្រូវទុកឱ្យ ព្រះរាជ្ញា ជនចោទជាប់ និង មេធាវី ។

[24] មាត្រា ២១ (២) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ជនជាប់ចោទដែលត្រូវបានឃុំឃាំង គឺមានសិទ្ធិពិសេសខុសពីសិទ្ធិទណ្ឌិត ព្រោះថាជនជាប់ចោទគេចាត់ទុកថាគ្មានកំហុស ហើយត្រូវទទួលការមើលថែយ៉ាងសមស្រប។ ជនជាប់ដែលឃុំឃាំងមុនពេលសវនាការត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីទណ្ឌិត[25] ។ ពន្ធនាគារត្រូវមានទំហំសមស្រប មានភ្លើង បង្គន់អនាម័យ និងឧបករណ៍សម្រាប់ងូតទឹកលាងសម្អាតខ្លួន ។ អ្នកជាប់ពន្ធនាគារត្រូវមានគែដាច់ដោយឡែក កន្លែងដេក និងសំលៀកបំពាក់ប្រកបដោយអនាម័យ ម្ហូបអាហារដែលមានជីវជាតិគ្រប់គ្រាន់សំរាប់ សុខភាព និងកំលាំងកាយ ទឹកបរិភោគ និងពេលមួយម៉ោងជារៀងរាល់ថ្ងៃដើម្បីហាត់ប្រាណ[26] ។

ក្រៅពីសិទ្ធិទាំងនេះ ជនជាប់ចោទនៅមានសិទ្ធិផ្សេងៗទៀតជាច្រើននៅក្នុងដំណាក់កាលនេះ ។

**ក. សិទ្ធិទទួលបានដំណឹងពីថ្ងៃជំនុំជម្រះ**

ដំណឹងពីថ្ងៃជំនុំជម្រះ គឺជាសិទ្ធិដែលសំខាន់មួយសម្រាប់ជនជាប់ចោទ។ តុលាការដែលមានសមត្ថកិច្ចត្រូវជូនដំណឹងពីថ្ងៃជំនុំជម្រះនេះអោយបានមុនរយៈពេល ១៥ថ្ងៃមុនថ្ងៃជំនុំជម្រះទៅមេធាវីរបស់ជនជាប់ចោទ ។

មាត្រា ២១ (២) នៃច្បាប់ព្រហទណ្ឌអន្តរកាលបានចែងថា " មេធាវី ត្រូវទទួលបានដំណឹង ១៥ថ្ងៃ មុនថ្ងៃជំនុំជម្រះកូនក្តីរបស់ខ្លួន" ។

ការជូនដំណឹងមុននេះគឺដើម្បីឱ្យជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ អាចធ្វើការរៀបចំ ពិនិត្យឯកសារផ្សេងៗ ឬរៀបចំប្រមូលនូវភស្តុតាងទាំងឡាយ សាក្សីនានាដើម្បីយកទៅការពារខ្លួនចំពោះមុខ ព្រះរាជអាជ្ញានៅពេលសវនាការឱ្យបានគ្រប់គ្រាន់ និងបានទាន់ពេលវេលា ព្រោះថាសាក្សីខ្លះអាចនៅឆ្ងាយពិបាកក្នុងការធ្វើដំណើរ ឬត្រូវប្រើរយៈពេលយូរ ។

**ខ. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេលយូរ**

សិទ្ធិនេះគឺជាគោលការណ៍មួយនៃនីតិវិធីព្រហ្មទណ្ឌ ដែលចេញមកពីការសន្មត់ទុកជាមុនថាគ្មានទោស គឺជាសិទ្ធិរបស់ជនជាប់ចោទក្នុងការ ទទួលបាននូវការជំនុំជម្រះនៅក្នុងរយៈពេលដ៏សមរម្យមួយដែលមិនពន្យាពេលយូរ[27] ។ ការជំនុំជម្រះជនជាប់ចោទក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើង បានចែងថា គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ក្តី ឬមិនជាប់ឃុំក្តី ត្រូវទទួលបានការកាត់ក្តី យ៉ាងយូរ បំផុត ៦ខែក្រោយពីថ្ងៃចាប់ខ្លួន ។

[25] មាត្រា ៨(ខ) នៃបទបញ្ញាតិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោស

[26] មាត្រា ១០,១៣,១៧,២១ ,៣៥ នៃបទបញ្ញាតិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោស

[27] មាត្រា១៤ ចំណុច ៣(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

ប្រសិនបើរយៈពេល ៦ខែមន្ត្រីដែលបានឃុំខ្លួនជនជាប់ចោទលើសរយៈពេលកំណត់ដោយច្បាប់ យ៉ាងនេះ គឺរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ហើយអាចត្រូវផ្តន្ទាទោស ។ ចំណែកជនជាប់ចោទត្រូវទទួលការដោះលែង ឬ យ៉ាងហោចណាស់អាចនិយាយតវ៉ាឱ្យលើកលែងការចោទប្រកាន់។ តាមគោលការណ៍សន្មតទុកជាមុនថាគ្មានទោស ជនជាប់ចោទត្រូវសន្មតទុកជាមុនថាគ្មានទោសរហូតដល់មានសាលក្រមជាស្ថាពរដូចនេះ ការពន្យាពេល ដើម្បីធ្វើការស៊ើបអង្កេត ឬការឃុំខ្លួនហួសកំណត់ដោយមិនបានបើកសវនាការ គឺជាការរំលោភបំពានមួយដែលមិនសមហេតុផល និងក៏ជាការរំលោភសិទ្ធិរបស់បុគ្គលផងដែរ ។

ការពន្យាពេលយូរក្នុងការនាំខ្លួនជនជាប់ចោទមកសវនាការ ជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់បុគ្គលដល់ដំណើរការសវនាការដោយយុត្តិធម៌ ពីព្រោះវាអាចមានបុរេវិនិច្ឆ័យចំពោះសមត្ថភាពជនជាប់ចោទក្នុងការបង្ហាញនូវការការពារឱ្យមានប្រសិទ្ធិភាព ។ ព្រោះថាសាក្សីសំខាន់ៗ អាចត្រូវបាន បាត់ខ្លួន ឬស្លាប់ ភស្តុតាងអាចបាត់បង់ ការរង់ចាំរបស់សាក្សីអំពីឧប្បត្តិហេតុដែលមិនគួរឱ្យជឿបាន... ដោយសារការពន្យាពេលយូរ អាចធ្វើឱ្យការជំនុំជម្រះមិនអាចប្រកបដោយភាពយុត្តិធម៌បាន ដូចនេះច្បាប់របស់កម្ពុជាបានកំណត់ថាត្រូវនាំខ្លួនជនជាប់ចោទមក ជំនុំជម្រះក្នុងរយៈពេល ៦ខែយ៉ាងយូរបន្ទាប់ពីពេលចាប់ខ្លួន ។

**គ. សិទ្ធិសុំឱ្យនៅក្រៅឃុំបណ្តោះអាសន្ន**

ជនជាប់ចោទ គឺអាចដាក់ពាក្យសុំអោយដោះលែងនៅក្រៅឃុំបណ្តោះអាសន្នបានយោងតាមមាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ " ជនជាប់ចោទមានសិទ្ធិសុំចៅក្រមឱ្យដោះលែងខ្លួននៅក្រៅឃុំបានគ្រប់ពេលវេលា ។ ក្នុងរយៈពេល ៥ថ្ងៃចៅក្រមត្រូវឆ្លើយតាមដីកាដែលមានចែងមូលហេតុ ។

ការដាក់ពាក្យសុំឱ្យនៅក្រៅឃុំបណ្តោះអាសន្ននេះ ជនជាប់ចោទគឺអាចធ្វើទៅបាននៅពេលដែល :

* ចៅក្រមខ្លះមិនបានពិចារណាទៅលើសំនួរថា តើត្រូវដោះលែង ឬត្រូវឃុំខ្លួនជនជាប់ចោទ ។

* ជនជាប់ចោទកំពុងជាប់ឃុំខ្លួនរង់ចាំសវនាការ ហើយចង់ឱ្យចៅក្រមធ្វើការពិនិត្យឡើងវិញអំពីការឃុំខ្លួននោះ ។

គ្រប់បណ្តឹងទាំងអស់ ដែលជនជាប់ចោទបានដាក់សុំឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ក្នុងរយៈពេល ៥ថ្ងៃចៅក្រមត្រូវឆ្លើយតាមរយៈដីកាដែលមានចែងអំពីមូលហេតុ ។ ប្រសិនបើជនជាប់ចោទ ឬភាគីដែលពាក់ពន្ធ័ (ដើមបណ្តឹងរដ្ឋប្បវេណី) ឬព្រះរាជអាជ្ញាមិនយល់ស្របទៅនឹងសេចក្តីសម្រេចនេះ គេអាចប្តឹងឧទ្ធរណ៍ក្នុងរយៈពេល៥ថ្ងៃ ។ សាលាឧទ្ធរណ៍ត្រូវសម្រេចអំពីបណ្តឹងនេះក្នុងរយៈពេល ១៥ថ្ងៃ ។ តែមាត្រា ២១៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧មិនបាននិយាយដូចគ្នាអំពីនីតិវិធីនៃការសុំដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ននេះទេ ។

**ឃ. សិទ្ធិប្តឹងជំទាស់ចៅក្រម**

ជាធម្មតាក្នុងដំណើការរឿងក្តីចំពោះតុលាការ អាចមានឧប្បត្តិហេតុកើតឡើងទាក់ទងទៅនឹងការចាត់តាំងចៅក្រម ដូចជាមានបណ្តឹងជំទាស់ជាដើម ។ ជនជាប់ចោទត្រូវធ្វើបណ្តឹងជំទាស់ចំពោះចៅក្រមយ៉ាងហោចណាស់៣ថ្ងៃ មុនពេលសវនាការ។ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧មិនបានចែងអំពីហេតុផលសម្រាប់បដិសេធចៅក្រម ដែលបានចាត់តាំងហើយនោះទេ។ ប៉ុន្តែបើយោងតាមច្បាប់ស្តីពីការរៀបចំអង្គតុលាការ ទាក់ទងនិងវិសមតភាព បានឱ្យនិយមន័យទៅលើការតវ៉ាពីរប្រភេទដែលបានប្រើដើម្បីបញ្ជាក់ថាចៅក្រម ឬតុលាការមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គឺមានបណ្តឹងបដិសេធ។

**បណ្តឹងជំទាស់ ៖** គឺជាបណ្តឹងដែលអនុញ្ញាតឱ្យភាគីធ្វើ ប្រសិនបើចៅក្រមម្នាក់ ឬច្រើននាក់ ដែលចាត់ការរឿងក្តីមិនបានអនុវត្តតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ រំលោភលើលក្ខន្តិកៈចៅក្រម ឬ ក្រមសីលធម៌របស់តុលាការ ។ ការរំលោភបំពានរបៀបនេះ ទាក់ទងទៅនឹងវិស័យការងាររបស់ចៅក្រមរួមមាន ៖

* ភាពមិនស្មោះត្រង់ ការតែបន្តំ ពុករលួយ ឬស៊ីសំណូកសូកប៉ាន់ នៅពេលបំពេញភារកិច្ចជា ផ្លូវការ

* បដិសេធមិនព្រមធ្វើការកាត់សេចក្តីរឿងដោយយកលេសថាមិនមានច្បាប់ដែលយកមកអនុវត្តបាន ឬថាច្បាប់នោះមិនច្បាស់លាស់ ឬមិនពេញលេញ

* ដោយមិនស្មោះត្រង់ និងមានបំណងអាក្រក់ មិនគោរពតាមគោលការណ៍ និង នីតិវិធីដែលតម្រូវឱ្យដោយអាជ្ញាធរតុលាការ

* មិនរកយុត្តិធម៌

**បណ្តឹងបដិសេធ ៖** ធ្វើឡើងសំដៅលើចៅក្រមម្នាក់ ច្រើននាក់ ឬតុលាការទាំងមូល ។ ភាគីអាចធ្វើការតវ៉ាចំពោះតុលាការទាំងមូល ប្រសិនបើចៅក្រមទាំងអស់នៅក្នុងតុលាការមានលក្ខណៈសម្បត្តិមិនគ្រប់គ្រាន់ ។ ចៅ ក្រមដែលមានលក្ខណៈសម្បត្តិមិនគ្រប់គ្រាន់នេះ អាចពាក់ព័ន្ធទៅនឹងស្ថានភាពដូចខាងក្រោម :

- ចៅក្រមមានផលប្រយោជន៍ផ្ទាល់ខ្លួនទាក់ទងទៅនឹងរឿងក្តី
- ចៅក្រមមានទំនាក់ទំនងជាមួយភាគីណាមួយក្នុងរឿងក្តី (រាប់ចាប់តាំងពីបងប្អូនជីទួតមួយ)
- មានបញ្ញត្តិពីសមត្ថភាព ( កន្លងមកក្នុងរឿងព្រហ្មទណ្ឌ បទឧក្រិដ្ឋ ឬ មជ្ឈិម ) រវាងចៅក្រម ឬគ្រួសារ ឬ សាច់ញាតិផ្ទាល់ណាមួយក្នុងរឿងក្តី ។
- រឿងក្តីរវាងភាគីម្ខាង និងគ្រួសាររបស់ចៅក្រម

- ចៅក្រមបានផ្តល់ដំបូន្មានជាលាយលក្ខណ៍អក្សរ ឬ អោយគំនិតអំពីរឿងក្តីដោយដើរទួនាទីជាចៅក្រម ស៊ើបសួរ ឬអាជ្ញាកណ្តាល ឬសាក្សី ឬបានទទួលអំណោយ ឬបានចូលរួមក្នុងពិធីផ្សេងៗ នៅលំនៅដ្ឋានរបស់ភាគី ដែលពាក់ព័ន្ធនៅក្នុងរឿងក្តី ។

នៅច្បាប់ស្តីពីការរៀបចំអង្គតុលាការ គឺពុំមានចែងហេតុផលបញ្ជាក់ដូចខាងលើនេះទេ តែបានចែងនូវមូលហេតុខ្លះៗដែលធ្វើឱ្យចៅក្រមខ្លះមិនបានចូលជាសមាជិកនៃតុលាការតែមួយទោះជា ចៅក្រមក្តី ជាតំណាងអយ្យការក្តី ។

" ញាតិសាលោហិតនិងញាតិពន្ធរហូតដល់ថ្នាក់ទី៤គិតបញ្ចូលផង មិនអាចធ្វើជាសមាជិកនៃតុលាការតែមួយបានទេ ក្នុងឋានៈជាចៅក្រមក្តី ជាតំណាងអយ្យការក្តី ។

គោលការណ៍នេះមិនគ្រាន់តែអនុវត្តទៅលើតុលាការខេត្ត-ក្រុងប៉ុណ្ណោះទេ គឺវាអនុវត្តទៅលើសាលាជំរះក្តីទាំងអស់ទោះជាថ្នាក់ណាក៏ដោយ " ។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គឺគេបានធ្វើការបែងចែកបណ្តឹងដែលមានលក្ខណៈដូចគ្នាជា២គឺបណ្តឹងដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជិតចិត្តចៅក្រម ។

**បណ្តឹងដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ ៖** គឺជាបណ្តឹងរបស់ភាគីណាមួយនៃរឿងក្តីចំពោះចៅក្រមដែលកំពុងកាន់រឿងក្តីរបស់ខ្លួនដោះស្រាយដោយមានមូលហេតុត្រូវនឹងគន្លងច្បាប់ ឬអាចនិយាយបានថាជាឧប្បត្តិហេតុ កើតចេញពីចៅក្រមផ្ទាល់ ជាហេតុធ្វើឱ្យភាគីនៃរឿងក្តីនោះមានការព្រួយបារម្ភថា នឹងមានភាពលំអៀងនៅក្នុងការសម្រេចសេចក្តី ។ មូលហេតុនីមួយ១នៃការប្តឹងសុំដកហូតចៅក្រមនេះមានបញ្ញត្តិច្បាស់លាស់នៅក្នុងច្បាប់ ។ មាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា : ក្នុងករណីដែលបានចែងកំណត់ដូចខាងក្រោមនេះ ចៅក្រមត្រូវដកហូតពីការអនុវត្តន៍មុខការរបស់ខ្លួន :

* កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រម ជាភាគីណាមួយនៅ ក្នុងរឿងក្តី

*កាលណាចៅក្រមជាញាតិលោហិតក្នុង៦ថ្នាក់ ឬ ញាតិពន្ធក្នុង៣ថ្នាក់ អតីតញាតិពន្ធក្នុង៣ថ្នាក់របស់ភាគីណាមួយ

* កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ

* កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ

* កាលណាចៅក្រមបានធ្វើជាសាក្សី ឬធ្វើជាអ្នកជំនាញក្នុងរឿងក្ដី

* កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយអោយភាគីចំពោះរឿងក្ដី

* កាលណាចៅក្រមបានចូលរួមសម្រេចសេចក្ដីមជ្ឈត្តករ ចំពោះរឿងក្ដីឬបានចូលរួមក្នុងការ សម្រេចសេចក្ដីទៅក្នុងការជំនុំជម្រះលើកទីមួយ ដែលមានឧប្រាស្រ័យ ឬការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញ មតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្ដី ។

**បណ្ដឹងជិតចិត្តចៅក្រម ៖** យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងនឹងបណ្ដឹងជិតចិត្តនេះ ក្នុងករណីដែលមានកាលៈទេសៈដែលបណ្ដាលអោយមានការលំអៀងក្នុងការជម្រះក្ដីចំពោះចៅក្រមណាម្នាក់នោះ ភាគីអាចប្ដឹងជិតចិត្តចៅក្រមនោះបាន[28]។

**១.៥ សិទ្ធិប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ**

ជាធម្មតាសិទ្ធិសេរីភាពក្នុងការជួបប្រាស្រ័យ ទាក់ទងគ្នាជាសិទ្ធិមួយដែលត្រូវបានទទួលស្គាល់ដោយប្រទេស ជាច្រើននៅលើសកលលោកបើទោះបីជាប្រទេសនោះប្រកាន់យករបបនយោបាយបែបណាក៏ដោយ ។ ជនជាប់ចោទ គឺជាជនមួយដែលត្រូវបានគេដកហូតនូវសិទ្ធិសំខាន់ៗមួយចំនួនចេញ តែសិទ្ធិក្នុងការប្រាស្រ័យទក់ទងគ្នាជាមួយ ឪពុក ម្ដាយ បងប្អូន មិត្តភក្តិ មិនត្រូវបានបាត់បង់នោះទេ ។ ជួនកាលនៅពេលដែលសាច់ញាតិជនជាប់ចោទមក សួរសុខទុក្ខគាត់អាចនាំមកនូវដំណឹងសំខាន់ៗ ឬភស្តុតាងនានាដែលមានប្រយោជន៍ ពោលគឺអាចជួយជនជាប់ចោទ អោយយកមកធ្វើជាសំអាងក្នុងពេលបើកសវនាការ ។ដូច្នេះជនជាប់ចោទ ជនសង្ស័យទាំងអស់ត្រូវតែបាន អនុញ្ញាត ឱ្យទាក់ទងជាមួយគ្រួសារ សាច់ញាតិ និង មិត្តភក្តិ ដែលគេសន្មតថាជាមនុស្សល្អតាមកាលកំណត់ជាទៀងទាត់ តាមរយៈសំបុត្រឆ្លើយឆ្លង ឬតាមរយៈ ការមកសួរសុខទុក្ខដោយផ្ទាល់ក្ដី ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការ ទាក់ទងជាមួយគ្រួសារ សាច់ញាតិ និងមិត្តភក្តិនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យជាចាំបាច់[29] ។

លើសពីនេះទៅទៀតជនជាប់ចោទ ត្រូវបានអនុញ្ញាតឱ្យជូនពត៌មានដល់គ្រួសាររបស់ខ្លួនអំពីការជាប់ឃុំឃាំង ហើយត្រូវផ្ដល់មធ្យោបាយសមរម្យ សម្រាប់ទាក់ទងជាមួយក្រុមគ្រួសារ និង មិត្តភក្តិរបស់គេ[30] ។

[28] មាត្រា ២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[29] មាត្រា ៣៧ បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោស

[30] មាត្រា ៩២ បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោស

ក៏ប៉ុន្តែផ្ទុយទៅវិញក្នុងការអនុវត្តន៍ជាក់ស្តែង ការយកប្រាក់ពីគ្រួសារអ្នកទោសដែលទៅសួរសុខទុក្ខគ្រួសារកំពុង ជាប់ឃុំក្នុងពន្ធនាគារខេត្ត-ក្រុង គឺមានការកើនឡើងគួរអោយកត់សំគាល់ ។ តាមការស្រាវជ្រាវបានរកឃើញថាគ្រួសារអ្នកទោស ទោះមាន ឬ ក្រក្តីត្រូវតែរកប្រាក់ដើម្បីធ្វើការសូកប៉ាន់ឰពន្ធនាគារ និងទិញសម្ភារៈសម្រាប់ទំនុកបម្រុងកូនចៅរបស់ខ្លួន ។ យ៉ាងហោចណាស់គ្រួសារអ្នកទោស ត្រូវចំណាយប្រាក់ចាប់ពី ២០០០០ រៀល ទៅ ៤០០០០រៀល ( ពីរម៉ឺនរៀលទៅ បួនម៉ឺនរៀល សម្រាប់គ្រួសារមួយក្នុងការចូលទៅជួបកូនចៅរបស់គេក្នុងពន្ធនាគារ ។ ចំណែកគ្រួសារដែលទៅជួបជាមួយអ្នកទោសទើបចូលថ្មីត្រូវចំណាយពី ១៥ដុល្លាទៅ៣០ដុល្លា។ រីឯអ្នកទោស ដែលត្រូវដោះលែងបណ្តោះអាសន្នក៏ត្រូវយកប្រាក់ពី ២០ដុល្លាទៅ៣០ដុល្លាបន្ថែមទៀតដែរសម្រាប់ថ្លៃរត់ការជាមួយមន្ត្រីថ្នាក់លើ។

ដូច្នេះយើងអាចសន្និតបានថា ក្នុងការអនុវត្តន៍ជាក់ស្តែងសិទ្ធិរបស់ជនជាប់ចោទសម្រាប់ធ្វើការប្រាស្រ័យទាក់ទងជាមួយគ្រួសារសាច់ញាតិ ត្រូវបានទទួលរងនូវការរំលោភបំពានពីភ្នាក់ងារអនុវត្តច្បាប់ ជាពិសេសគឺមន្ត្រីពន្ធនាការតែម្តង ។

# ជំពូកទី២ ៖ សិទ្ធិការពារខ្លួនក្នុងពេល សវនាការ

## ជំពូកទី២៖ សិទ្ធិការពារខ្លួនក្នុងពេលសវនាការ

ការធ្វើសវនាការជំនុំជម្រះដល់ជនជាប់ចោទ គឺជាផ្នែកមួយដែលសំខាន់បំផុតនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ព្រោះថា មានតែពេលនេះហើយ ដែលជនជាប់ចោទត្រូវបានគេរកឃើញថា មានទោស ឬគ្មានទោសលើបទចោទ ដែលបានចោទប្រកាន់មកលើខ្លួន ។ ការជំនុំជម្រះគឺជាឱកាសតែមួយ ដែលជនជាប់ចោទត្រូវតវ៉ាអំពីការចោទប្រកាន់មកលើខ្លួន តាមរយៈការសាកសួរសាក្សីដាក់បន្ទុក ពិនិត្យភស្តុតាងដាក់បន្ទុក កោះហៅសាក្សីដែលអាចបង្ហាញពី វិមតិសង្ស័យទៅលើភស្តុតាងដាក់បន្ទុក របស់តំណាងអយ្យការ និង បង្ហាញជូនទៅតុលាការ នូវការបកស្រាយផ្ទាល់ខ្លួនទៅលើអង្គហេតុ និងអង្គច្បាប់ ។ យើងអាចនិយាយបានថា សវនាការជំនុំជម្រះ គឺជាឱកាសមួយរបស់ ជនជាប់ចោទដើម្បីដាក់ជូននូវសណ្ឋានការពាររបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញា ។

ក្រៅពីនេះនៅក្នុងសវនាការ ជនជាប់ចោទមានសិទ្ធិជាច្រើនទៀតដែលត្រូវទទួលបានដូចជា :

### ២.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

បញ្ហាដែលសំខាន់បំផុតក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺជាសមត្ថកិច្ចតុលាការក្នុងការធានាថាជនជាប់ចោទទទួលនូវសវនាការមួយប្រកបដោយ ភាពយុត្តិធម៌ ។ ចំណុចមួយដែលច្បាស់បំផុតក្នុងបញ្ញត្តិនៃសវនាការយុត្តិធម៌ គឺគោលការណ៍សមភាពរវាង ការការពារនិងការចោទប្រកាន់ ត្រូវមានឋានៈស្មើគ្នា សិទ្ធិស្មើគ្នា និងឱកាសស្មើគ្នា នៅក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន ។ សវនាការប្រកបដោយយុត្តិធម៌ អាចធ្វើឡើងដោយចៅក្រមដែលមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង ។ ជារួមយើងអាចនិយាយបានថាចៅក្រមជំនុំជម្រះមានសមត្ថភាពប្រសិនបើចៅក្រមរូបនោះបានទទួលនូវការហ្វឹកហ្វឺនត្រឹមត្រូវ មានចំនេះដឹងល្អផ្នែកច្បាប់ និងមានការប៉ិនប្រសព្វ និងជំនាញក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន ។ ចៅក្រមឯករាជ្យ គឺជាអ្នកដែលមិនស្ថិតក្រោមឥទ្ធិពល ការដាក់កម្រិត ឬការគាបសង្កត់ពីបុគ្គល ឬ ពីអង្គការណាមួយ ដោយមានសេរីភាពគ្រប់គ្រាន់ ក្នុងការចេញសេចក្តីសម្រេចដោយ មិនមានការភ័យខ្លាចពីផលវិបាក ឬ សេចក្តីរំពឹងទុកថាមានភាពលំអៀង ។ ចៅក្រម មិនលំអៀង គឺអ្នកដែលមិនកាន់ជើងតំណាងអយ្យការ ឬមេធាវីការពារ ប៉ុន្តែត្រូវប្រកាន់យកភាព កណ្តាល អព្យាក្រឹត្យ ហើយប្រកាន់យក តែភាពយុត្តិធម៌ និងភាពត្រឹមត្រូវ ។

រដ្ឋធម្មនុញ្ញ និងច្បាប់របស់កម្ពុជាដទៃទៀត ក៏ដូចជាច្បាប់អន្តរជាតិផងដែរ ចែងពីគោលការណ៍ទូទៅស្តីពីសវនាការមួយប្រកបដោយលក្ខណៈយុត្តិធម៌ :

មានតែចៅក្រមទេទើបមានសិទ្ធិកាត់សេចក្តីចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់ដោយ ត្រឹមត្រូវ និងប្រកបដោយសតិសម្បជញ្ញៈ[31] ។

គោលការណ៍ឯករាជ្យនៃអំណាចតុលាការតម្រូវឱ្យចៅក្រមធានាឱ្យដំណើរការតុលាការប្រព្រឹត្តទៅដោយយុត្តិធម៌ និងគោរពសិទ្ធិទាំងឡាយរបស់ភាគី[32] ។

ជនគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ ។ ក្នុងសម្រេចអំពីបទចោទព្រហ្មទណ្ឌប្រឆាំងនឹងការកាត់...... ជនគ្រប់រូបមានសិទ្ធិទទួលសវនាការប្រកបដោយយុត្តិធម៌ ដោយតុលាការ មានសមត្ថភាព ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់......[33] ។

អំណាចតុលារការត្រូវធានា និងប្រកាន់ខ្ជាប់នូវភាពមិនលំអៀង ហើយការពារសិទ្ធិ និងសេរីភាព របស់ប្រជាពលរដ្ឋ[34] ។

ចៅក្រមត្រូវសម្រេចឱ្យបាននូវភាពមិនលំអៀងទាំងស្រុង ដោយផ្អែកលើមូលដ្ឋានអង្គហេតុ ដែលលើកឡើងហើយស្របតាមច្បាប់ដោយបដិសេធនូវសំពាធ ទាំងឡាយដែលតាមគំរាមកំហែង ឬការបំភិតបំភ័យដោយផ្ទាល់ ឬ ដោយប្រយោល ដោយភាគីទាំងឡាយក្នុងដំណើការ ឬជនណាដទៃទៀត ។

តុលាការព្រហ្មទណ្ឌដើម្បីពង្រឹងជំនឿ របស់ខ្លួនអាចពិនិត្យទៅលើគ្រប់ឯកសារទាំងអស់ដែលបានដាក់ដើម្បីឱ្យសួរដេញដោលនៅពេលសវនាការ និងដាក់ឱ្យសួរតទល់រវាងគូរភាគី និង មេធាវីដើម្បីចេញសាលក្រម ។ ចៅក្រមមិនត្រូវផ្អែកជំនឿរបស់ខ្លួន ទៅលើការដឹងលឺផ្ទាល់ខ្លួន ដែលខ្លួនបានទទួលក្រៅពីសវនាការក្នុងតុលាការឡើយ[35] ។

អំណាចតុលាកាត្រូវតែជាអំណាចឯករាជ្យ ពីអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ ហើយនិងពីគណបក្សនយោបាយ...... ។

[31] មាត្រា ១២៩(២) នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣
[32] មាត្រា ១(៣) នៃច្បាប់ព្រហ្មទណ្ឌអន្តរការ
[37] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[34] មាត្រា ១២៨(២) នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣
[35] មាត្រា ១២៥(២) នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ២៩ មករា ឆ្នាំ១៩៩៣

## ២.២ សិទ្ធិទទួលបានការជំនុំជម្រះដោយសាធារណៈ

សិទ្ធិទទួលបានការជំនុំជម្រះដោយសាធារណៈ មិនត្រឹមតែកើតចេញពីគោលការណ៍ ដែលថារកយុត្តិធម៌បាន ដោយវិធីណានោះទេ គឺថែមទាំងទាមទារអោយមើលឃើញការរកយុត្តិធម៌នេះទៀតផង ។ តាមការយល់ដឹងជារួមការរំលោភសិទ្ធិមនុស្ស និងរំលោភលើនីតិវិធី អាចកើតឡើងភាគច្រើននៅក្នុងសវនាការដែលធ្វើឡើងជាសំងាត់ ជាជាងសវនាការដែលធ្វើឡើងជាសាធារណៈ ដែលដំណើការរួមរបស់វាត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីមហាជន ។ អាចនិយាយបានថា សវនាការជាសាធារណៈមានផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ដោយសារថា បានដឹងលឺច្រើនក្នុងចំណោមមហាជន នូវឥទ្ធិពលនៃការធ្វើឱ្យរាងចាល ទាំងក្នុងពេលសវនាការ និងក្នុងពេលកាត់ទោសជនល្មើស ។ ផ្នែកមួយសំខាន់ ក្នុងការកាត់ទោសពិរុទ្ធជន គឺការធ្វើឱ្យគេទទួលនូវភាពអាម៉ាស់ពីមហាជន ដែលអាចធ្វើឡើងក្នុងពេលបើកសវនាការជាសាធារណៈ ។

គោលការណ៍ជំនុំជម្រះជាសារធារណៈ គឺធ្វើនៅក្នុងបន្ទប់សវនាការដែលបើកគឺមិនបិទទេដោយអនុញ្ញាតឱ្យអ្នកដែលគ្មានការពាក់ពន្ធ័ ឬប្រជាពលរដ្ឋទាំងអស់ អាចចូលរួមស្តាប់បានគឺដើម្បី :

* ឱ្យតុលាការយកចិត្តទុកដាក់ នូវការជំនុំជម្រះរបស់ខ្លួនឱ្យកាន់តែត្រឹមត្រូវ

* ធ្វើការផ្សព្វផ្សាយទៅអ្នកចូលរួមឱ្យមានការយល់ដឹង ផ្សព្វផ្សាយច្បាប់ និង ការអនុវត្តន៍ច្បាប់ :

- យល់ដឹងឱ្យបានកាន់តែស៊ីជម្រៅ

- បើដំណើការកាត់ក្តីបានត្រឹមត្រូវ នាំអោយមានការយកចិត្តទុកដាក់ពីស្ថាប័នតុលាការ

- អ្នកដែលមានបំណងចង់ធ្វើបំពាននាំអោយខ្លាចមិនធ្វើដោយសារខ្លាចច្បាប់

សិទ្ធិក្នុងការទទួលសវនាការជាសាធារណៈ មានចែងយ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជា[36] ហើយមានករណីលើកលែងតែមួយចំនួនប៉ុណ្ណោះ ។ ច្បាប់រដ្ឋកម្ពុជាតម្រូវឱ្យបើកសវនាការជាសម្ងាត់ប្រសិនបើការបើកសវនាការនៅក្នុងតុលាការជាសារធារណៈអាចមានគ្រោះថ្នាក់ដល់របៀបរៀបរយសារធារណៈ និង ប្រពៃណីល្អ[37]។ ទាក់ទងទៅនឹងប្រពៃណីល្អនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ អាចឱ្យបើក សវនាការជាសម្ងាត់បានប្រសិនបើជនរងគ្រោះ តំណាងរបស់ខ្លួនស្នើរហើយមានការឯកភាពពីចៅក្រម[38] ។ ហេតុដែលបើកសវនាការជាសម្ងាត់រួមមាន :

[36] មាត្រា៣១៦ ១២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧តម្រូវឱ្យបើកសវនាការជាសារធារណៈ និងមាត្រា១៦(២)សវនាការឬសាលក្រមដែលមិនធ្វើឡើងជាសារធារណៈត្រូវចាត់ទុកជាមោឃ។

[37] មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[38] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

* ពេលមានការខឹងសម្បាពីចំណោមមហាជន ដែលអាចបង្ករចលាចល ឬអំពើហឹង្សា (ដែលអាចការមានផលប៉ះពាល់ដល់សន្តិសុខ របៀបរៀបរយសារធារណៈ)

* ការពារអត្តសញ្ញាណ និងសុវត្ថិភាពសាក្សី

* ពេលជនរងគ្រោះស្នើរអោយមានសវនាការជាសម្ងាត់ ហើយតុលាការយល់ព្រម ។

## ២.៣ សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះ

ការជំនុំជម្រះដែលដំណើរការដោយគ្មានវត្តមានរបស់ជនជាប់ចោទ គឺជាការរំលោភលើគោលការណ៍សវនាការប្រកបដោយយុត្តិធម៌ដូចដែលបានរៀបរាប់ខាងលើរួចមកហើយ ។ អវត្តមានរបស់ជនជាប់ចោទ មិនអាចឱ្យមានការទទួលដំណឹងពីបទចោទប្រកាន់ មិនអាចមានសិទ្ធិជូនសំអាងការពារ មានឬគ្មានជំនួយ ពីមេធាវី និង មិនអាចហៅសាក្សីមកសួរដេញដោល និងឆ្លើយបំភ្លឺបានទេ ។ ដូចគ្នានេះដែរវាជាការមួយបាត់បង់នូវសមភាពរវាង ការចោទប្រកាន់ និងការការពារក្តី ព្រោះថាបែបនេះ ការការពារនិងមិនអាចធ្វើទៅបាននោះទេ ។

មាត្រា ៣៦២ ដល់មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងអំពីនីតិវិធីជំនុំជម្រះនៃជនជាប់ ចោទអវត្តមានដែលហៅថា ការជំនុំជម្រះកំបាំងមុខ ។ ជនជាប់ចោទអាចជំទាស់ និង សេចក្តីសម្រេចរបស់តុលាការក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងពីសាលក្រមកំបាំងមុខកាលណាសាលក្រមនេះមិនបានប្រគល់ដល់ពិរុទ្ធដោយផ្ទាល់ដៃទេ ឬ ពីថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ដល់ពិរុទ្ធដោយផ្ទាល់ដៃទេ[39]។ នៅមានសុពលភាព ប្រសិនបើជនជាប់ចោទមិនបាន ទទួល ឬមិនបានគេប្រាប់ដំណឹងអំពីសាលក្រុមនោះ ។

សិទ្ធិរបស់ជនជាប់ចោទ ក្នុងការមានវត្តមាននៅសវនាការមានចែងយ៉ាងច្បាស់ នៅក្នុងបទដ្ឋានជាអប្បបរមារបស់អន្តរជាតិ[40]។ ធីតិវិធីជំនុំជម្រះកំបាំងមុខ មានលក្ខណៈផ្ទុយទៅនិងរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលមានចែងដូចខាងក្រោម :

* ប្រជាពលរដ្ឋគ្រប់រូប ត្រូវបានទទួលនូវសិទ្ធិទទួលការការពារពីតុលាការ[41] ។

[39] មាត្រា ៣៦៨. នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[40] មាត្រា ១១ (១) នៃសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស និងមាត្រា ១៤ (៣ ឃ) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[41] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

* ការជំនុំជម្រះការកាត់ទោសត្រូវធ្វើចំពោះមុខសាមីជន ។ សាមីជនអាចឆ្លើយដោះសារដើម្បី ការពារខ្លួនដោយខ្លួនឯង ឬដោយជំនួយផ្នែកច្បាប់ដែលគាត់ជាអ្នកជ្រើសរើស[42] ។

ប៉ុន្តែយើងអាចលើកឡើងបានថា ការការពារនេះមិនអាចការពារមាត្រា៣៦៥ដល់មាត្រា៣៧២ ដូចដែលគេបានលើកឡើងក្នុងនីតិវិធីសាលក្រមកំបាំងមុខនោះបានទេ ព្រោះវាផ្ទុយនិងស្មារតីនៃរដ្ឋធម្មនុញ្ញ ហើយដែលមាត្រាទាំងនោះ មិនអាចមានអំណាចអនុវត្តជាច្បាប់តទៅទៀតបានឡើយ ។

## ២.៤ សិទ្ធិមានអ្នកបកប្រែភាសា

នៅក្នុងសវនាការសិទ្ធិមានអ្នកបកប្រែភាសា គឺជាការចាំបាច់សម្រាប់ភាគី ឬសម្រាប់ជនជាប់ចោទ ។ ភាគីត្រូវមានជំនួយការដោយឥតគិតថ្លៃ នូវអ្នកបកប្រែផ្ទាល់មាត់ដែលមានសមត្ថភាព ហើយការបកប្រែនោះចាំបាច់ដើម្បីបំពេញបានតាមលក្ខខ័ណ្ឌតម្រូវមានភាពយុត្តិធម៌ ប្រសិនបើដំណើរការរឿងក្តី ឬឯកសារណាមួយដែលបានបង្ហាញដល់ តុលាការមិនធ្វើឡើងជាភាសាដែលជនជាប់ចោទយល់ និងនិយាយបានយ៉ាងពេញលេញទេនោះ ។ ដូច្នេះគឺត្រូវមានអ្នកបកប្រែភាសា សំរាប់ជួយដោយឥតគិតថ្លៃឈ្នួល ប្រសិនបើសាម៉ីជនមិនចេះស្តាប់ភាសាដែល ប្រើក្នុងការកាត់ក្តីនេះ[43] ។ ដូចនេះនៅក្នុងសវនាការតុលាការ ត្រូវតែរកអ្នកបកប្រែជូនភាគីនៅក្នុងរឿងក្តី ដែលមិនចេះភាសា ឬជាជន គ ថ្លង់ ។ តាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣ មាត្រា ១៣៦បានចែងថា " បើជនជាប់ចោទ ឬ សាក្សីជាមនុស្ស គ ថ្លង់ ប៉ុន្តែចេនសរសេរអក្សរនោះ ក្រឡាបញ្ជីត្រូវសរសេរសំនួរ និងការកត់សំគាល់ផ្សេងៗ ទៅ អោយជនជាប់ចោទ ឬសាក្សី គ ថ្លង់ នោះ ដើម្បីអោយឆ្លើយមកវិញដោយលាយលក្ខណ៍អក្សរ ។ បើជន គ ថ្លង់ មិនចេះសរសេរអក្សរ ចៅក្រមត្រូវតែងតាំងដោយឯកឯងនូវជនណាម្នាក់ដែលមានទំលាប់ទាក់ទងមនុស្ស គ ថ្លង់ ដោយកាយវិការ ដើម្បីធ្វើជាអ្នកបកប្រែ " ។

ដូច្នេះយើងឃើញថានៅប្រទេសកម្ពុជាយើង ក៏មានការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ផងដែរនូវសិទ្ធិមាន អ្នកបកប្រែភាសាសម្រាប់ផ្តល់ជូនភាគី ឬក៏សម្រាប់ជនជាប់ចោទ ដូចជាតាមរយៈលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលបានរៀបរាប់ខាងលើ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ព្រោះថារដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានប្រកាសយ៉ាងទូលំទូលាយ ក្នុងការទទួលស្គាល់នូវលិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិទាំងអស់នេះ[44] ។

[42] មាត្រា ១៤ (៣ ឃ) នៃកតិកាសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ

[43] មាត្រា ១៤ (២ ច) នៃកតិកាសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ

[44] មាត្រា ៣១ (១) នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

# ជំពូកទី៣ ៖ សិទ្ធិជនជាប់ចោទក្រោយពេលសវនាការ

## ជំពូកទី៣ សិទ្ធិជនជាប់ចោទក្រោយពេលសវនាការ

នៅក្រោយពេលដែលចៅក្រមជំនុំជំរះរួច ទោះបីជាសាលក្រម ឬសាលដីការបស់តុលាការ ខេត្ត-ក្រុង ឬសាលាឧទ្ធរណ៍សំរេចចេញមកយ៉ាងណាក៏ដោយ ក៏យើងនៅតែមានសិទ្ធិតវ៉ា ដាក់ពាក្យប្ដឹងទាស់ទៅនឹងសាលក្រម ឬសាលដីកា ឬក៏ប្ដឹងសារទុកទៅតុលាការកំពូល បើសិនជាយើងមិនអស់ចិត្ត ឬ មិនយល់ព្រមចំពោះការ សំរេចទាំងនោះ ។ ព្រោះថារាល់បណ្ដឹងទាំងនេះ (បណ្ដឹងជំទាស់ និងបណ្ដឹងសារទុក្ខ) មានអានុភាពផ្អាកនូវការ អនុវត្តន៍សាលក្រម ឬសាលដីកាទាំងនោះបាន ។

### ៣.១ បណ្ដឹងទាស់

បណ្ដឹងទាស់ ឬបណ្ដឹងជំទាស់គឺជាពាក្យសុំបដិសេធសេចក្ដីសម្រេច ឬសាលក្រម ដែលត្រូវបើកឱ្យគូក្ដីដែល បានអវត្តមាននៅពេលជំនុំជំរះ ដោយសុំអោយមានការជុំនំជរះជាថ្មីឡើងវិញចំពោះមុខខ្លួន ។ ពាក្យបណ្ដឹងទាស់នោះ គឺប្រើសំរាប់ប្ដឹងអំពីសេចក្ដីសម្រេចកំបាំងមុខរបស់សាលាជម្រះក្ដី[45] ។

ជនជាប់ចោទមានសិទ្ធិប្ដឹងជំទាស់ទៅនឹងសាលក្រមកំបាំងមុខថា សវនាការមួយដែលបានប្រព្រឹត្តទៅដោយអវត្តមានជនជាប់ចោទ មិនមែនជាសវនាការប្រកបដោយគតិយុត្តិធម៌នោះឡើយ។ វាគឺជាការរំលោភលើសិទ្ធិជនជាប់ចោទ ក្នុងការទទួលបាននូវការជូនដំណឹងពីបទចោទ រៀបចំការពារក្ដី មាន ឬគ្មានជំនួយពីមេធាវី និង ការហៅសួរសាក្សីមកបំភ្លឺ។ ពោលគឺមិនអាចមានសមភាពរវាងតំណាងអយ្យការ និងមេធាវីការពារបានទេ ព្រោះមិនអាចលើកសណ្ឋានការពារបាន ។

ជនជាប់ចោទអាចប្ដឹងទាស់ និងសាលក្រមកំបាំងមុខនេះបានក្នុងរយះពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃបានជូនដំណឹងដល់ខ្លួនដោយផ្ទាល់។ ការជំទាស់ស្របច្បាប់រយះពេល ១៥ថ្ងៃនេះគឺផ្អាកការអនុវត្តន៍សាលក្រម[46] ។ ប្រសិន បើមិនអាចជូនដំណឹងដោយផ្ទាល់មាត់អំពីសេចក្ដីប្រកាសនៃសាលក្រមនេះ សាលក្រមនេះអាចយកទៅបិទនៅ នឹងលំនៅដ្ឋានដែលគេស្គាល់ចុងក្រោយបង្អស់របស់ជនល្មើស ឬបិទនូវឃុំសង្កាត់ ឬផ្សាយតាមវិទ្យុជាតិ ឬបោះពុម្ព ផ្សាយតាមសាពត៌មានផ្លូវការ ។ ប្រសិនបើជនជាប់ចោទ ដឹងអំពីសាលក្រម គាត់អាចប្ដឹងទាស់នៅពេលណាក៏ បាន ក្នុងកំឡុងពេលអាជ្ញាយុកាលនៃទោស ។

ប្រសិនបើជនជាប់ចោទប្ដឹងទាស់ ហើយតុលាការទទួលបណ្ដឹងនោះសំណុំរឿងរបស់ជនជាប់ចោទ ត្រូវបាន យកទៅជំនុំជំរះនៅចំពោះមុខតុលាការ ដោយចាត់ការដូចជាការជំនុំជំរះលើកទីមួយ ។ មានន័យថាកម្រិតនៃស្ថានទំងន់ទោស អាចត្រូវបានគេលើកយកមកពិចារណាម្ដងទៀត បើមិនមានលើកឡើងនៅក្នុង សាលក្រម

[45] វចនានុក្រមច្បាប់ លោក ហ៊ឹង ធីឫទ្ធិ ឆ្នាំ ២០១៤

[46] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

កំបាំងមុខហើយជនជាប់ចោទដែល បានកាត់ទោសរួចហើយនោះក៏អាចសំរេចឱ្យរួចខ្លួនវិញបានដែរ ។ប្រសិនបើជនជាប់ ចោទមិនមកបង្ហាញខ្លួននៅពេលសវនាការថ្មីនេះទេ ការជំនុំជំរះកំបាំងមុខនាពេលមុន ត្រូវចាត់ទុកថាបានធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ [47]។

### ៣.២ សិទ្ធិប្តឹងឧទ្ធរណ៍

សិទ្ធិប្តឹងឧទ្ធរណ៍ គឺជាពាក្យតវ៉ារបស់ភាគីណាមួយ ដែលប្តឹសុំឱ្យកែប្រែសេចក្តីសម្រេច ឬសាលក្រមរបស់ តុលាការខេត្ត-ក្រុង ។ សេចក្តីសម្រេចទាំងឡាយរបស់អយ្យការអមតុលាការទាំងនេះ ត្រូវបើកសវនាការនៅតុលាការជាន់ខ្ពស់ដែលហៅថា សាលាឧទ្ធរណ៍ ដែលមានចំនួន៤គឺ សាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍តំបន់បាត់ដំបង សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និង សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ ដែលមានដែនសមត្ថកិច្ចទៅតាមតំបន់របស់សាលាឧទ្ធរណ៍នីមួយៗ នៃព្រះរាជាណាចក្រកម្ពុជា ។

សាលាឧទ្ធរណ៍ពិនិត្យឡើងវិញ ទាំងលើអង្គហេតុ និងអង្គច្បាប់ ។ ដូច្នេះបើសិនជាភាគីណាមួយ មិនពេញចិត្តនឹងសាលក្រម ឬសេចក្តីសម្រេចរបស់តុលាការជាន់ទាប ភាគីនោះអាចរៀបចំសំណុំរឿងដើម្បីប្តឹងទៅសាលាឧទ្ធរណ៍ ។ បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល១ខែ ចាប់ពីថ្ងៃដែលប្រកាសសាលក្រម[48] ។

សាលាឧទ្ធរណ៍ប្រើប្រាស់នីតិវិធីសវនាការ ដូចគ្នានិងនីតិវិធីដែលប្រើនៅក្នុងតុលារការខេត្ត-ក្រុងដែរ តែចំណុចដែលខុសគ្នានោះ គឺថារឿងក្តីត្រូវជំនុំជម្រះដោយចៅក្រម ៣រូប ហៅថាក្រុមប្រឹក្សាជំនុំជម្រះ និងធ្វើការស៊ើបអង្កេតបន្ថែមដើម្បីជួយរកដំណោះស្រាយ អំពីការខ្វះចន្លោះលើអង្គហេតុ ដែលរកឃើញ ដោយតុលារថ្នាក់ទាប ។ សាលាឧទ្ធរណ៍អាចសម្រេចដំកល់សេចក្តីសម្រេចរបស់តុលាការជាន់ទាបទាំងមូល ឬដោយផ្នែក ឬអាចកែតម្រូវចំណុចខ្លះ នៅក្នុងសាលក្រម ឬបដិសេធទាំងស្រុង ។ ប៉ុន្តែសាលាឧទ្ធរណ៍មិនអាចបើកសវនាការលើបញ្ហា និងបទចោទដែល មិនបានប្តឹងឧទ្ធរណ៍នោះទេ ។ សាលាឧទ្ធរណ៍ក៏មានដែនអំណាច ក្នុងការបើកសវនាការលើបណ្តឹងឧទ្ធរណ៍ដែល អយ្យការតុលាការខេត្ត-ក្រុងជាអ្នកប្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចទាំងឡាយ របស់ចៅក្រមនៅតុលាការទាំងនោះ ទាក់ទងទៅនឹងការឃុំខ្លួន ឬការឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ឬលើសេចក្តីសម្រេចលើក លែងការចោទប្រកាន់ ដោយគ្មានមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ ។

ក្នុងកំឡុងពេលប្តឹងឧទ្ធរណ៍ និង ក្នុងរយៈពេលជំនុំជម្រះឧទ្ធរណ៍ការអនុវត្តន៍សាលក្រមដែលសម្រេចឡើងដោយតុលាការជាន់ទាបត្រូវផ្អាក ។

---

[47] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[48] មាត្រា ៣៨១,៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ក្នុងរឿងក្តីព្រហ្មទណ្ឌ ការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេច ឬ សាលក្រមណាមួយដែលចេញដោយតុលាការថ្នាក់ក្រោម ត្រូវធ្វើឡើងនូវការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលបានកាត់សេចក្តីលើរឿងនោះ ។ ដើមបណ្តឹងឧទ្ធរណ៍ មិនតម្រូវឱ្យបង់ប្រាក់ប្រដាប់ក្តី ដូចក្នុងរឿងរដ្ឋប្បវេណីនោះទេ ។

ក្នុងករណីជនជនជាប់ចោទជាអ្នកប្តឹងឧទ្ធរណ៍ក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ គឺតម្រូវឱ្យសាលាឧទ្ធរណ៍គោរពតាមគោលការណ៍ដូចខាងក្រោម :

* សាលាឧទ្ធរណ៍មិនអាចដាក់ទោសធ្ងន់ធ្ងរបន្ថែម ទៀតជាងអ្វីដែលតុលាការជាន់ទាបបានសំរេចម្តងហើយនោះទេ ។ សាលាឧទ្ធរណ៍អាចត្រឹមតែធ្វើការកែតំរូវសាលក្រមដើម្បីឱ្យ ជនជាប់ចោទបានទទួលនូវអត្ថប្រយោជន៍ ។

* សាលាឧទ្ធរណ៍អាចផ្លាស់ប្តូរបទល្មើស ដែលសម្រេចដោយតុលាការជាន់ទាប ប៉ុន្តែការផ្លាស់ប្តូរនោះអាច ធ្វើទៅបានតែក្នុងករណី មិនបន្ថែមទម្ងន់ទោសដល់ជនជាប់ចោទ ។ ដូចគ្នានេះដែរការផ្លាស់ប្តូរអំពីលក្ខណៈសម្បត្តិ នៃបទល្មើសអាចធ្វើទៅបាន តែក្នុងករណីមិនលើកយកធាតុផ្សំនៃអង្គហេតុ ដែលមិនមានបង្ហាញនៅតុលាការ ជាន់ទាប[49] ។

* សាលាឧទ្ធរណ៍អាចយកច្បាប់ព្រហ្មទណ្ឌ ឬ ឯកសារច្បាប់ផ្សេងទៀតខុសពីអង្គច្បាប់ដែលតុលាការជាន់ទាបយកមកអនុវត្តលើអង្គហេតុដដែល ប៉ុន្តែសាលាឧទ្ធរណ៍មិនអាចបង្កើន កម្រិតទោសដែលបានសម្រេចដោយតុលាការជាន់ទាបបានទេ ។

* សាលាឧទ្ធរណីមិនអាចបន្ថែមអនុទោសលើមូលទោសបានទេ ។ ប្រសិនបើសាលាឧទ្ធរណ៍ សម្រេចថា ឯកភាពជាមួយ និងសាលក្រមរបស់តុលាការជាន់ទាប ហើយប្រសិនបើអយ្យការតុលាការជាន់ទាប មិនបានស្នើឱ្យបន្ថែមអនុទោស សាលាឧទ្ធរណ៍ត្រូវពន្យល់ឱ្យបានច្បាស់នៅក្នុងដីកាថា មិនអាចបន្ថែមអនុទោសបានទេ ព្រោះថា បណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយជាប់ចោទ ហើយអយ្យការនៅតុលាការថ្នាក់ទាបមិនបានស្នើឱ្យបន្ថែមលើមូលទោសនោះទេ ។ ប្រសិនបើសាលាឧទ្ធរណ៍ឯកភាពនឹងសាលក្រម របស់សាលាដំបូងដោយមិនបានបញ្ជាក់ថាហេតុអ្វីបានជា មិនមានការបន្ថែមអនុទោស សាលដីការបស់សាលាឧទ្ធរណ៍នោះត្រូវចាត់ទុកថាមានកំហុស ហើយត្រូវប្រកាសថា ជាមោឃៈ ។

[49] មាត្រា ១៦៤ ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

**អនុទោស ៖** អនុទោស ឬ ទោសបន្ថែម គឺជាទោសដែលតុលាការប្រកាសបន្ថែមទៅលើមូលទោស។ ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវ ប្តាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

អនុទោស ឬទោសបន្ថែម មិនត្រូវបានបញ្ញត្តិក្នុងលក្ខណៈជាទូទៅដោយច្បាប់វិជ្ជមានបច្ចុប្បន្នទេ... ប៉ុន្តពុំមែនបានន័យថា គ្មានអនុទោសនៅក្នុងច្បាប់ខ្មែរសព្វថ្ងៃឡើយ ។ អនុទោសដែលយកផ្ទុនាបាន គឺអនុទោសដែល មានចែងនៅក្នុងច្បាប់ ហើយតុលាការជាអ្នកមានសមត្ថកិច្ចប្រកាសទោសនោះ ។

តុលាការអាចបញ្ជាឱ្យបិទផ្សាយនូវសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយណា ដែលតុលាការនឹងបញ្ជាក់ ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយ ឬច្រើនដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កម្រឹតច្រើនបំផុត ១០ លានរៀល ។

ការបញ្ញាត្តិជាទូទៅស្តីពីបញ្ហានេះ មានកំណត់យ៉ាងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩[50] ។

មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌរៀបរាប់ពីទោសបន្ថែមដូចតទៅ :

១. ការដកសិទ្ធិខ្លះពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះ បាន

ប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

[50] មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិត ដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុង គ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

ដោយ ប្រកាសទោសបន្ថែមមកជំនួសវិញ ។ ការប្រកាសទោសបន្ថែមជំនួសមូលទោស អាចប្រព្រឹត្តទៅ បានក្នុងករណី ខាងក្រោម :

- ជនជាប់ចោទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

- កាលណាជនជាប់ចោទទួលទោសជាប់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ឆ្នាំ[51] ។

[51] នីតិព្រហ្មទណ្ឌទូទៅ លោក រុន ពណ្ណារិទ្ធិ ឆ្នាំ ២០២២

សាលាឧទ្ធរណ៍មិនអាចបន្ថែមចំនួនទឹកប្រាក់ សម្រាប់ជួសជុលការខូចខាត់ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីបាននោះទេ[52] ។

សាលាឧទ្ធរណ៍អាចប្រកាសទោលបន្ថែម ដែលដាច់ខាតត្រូវតែប្រកាសដោយខានមិនបានដែលតុលាការជាន់ដំបូងភ្លេចមិនបានប្រកាស [53] ។

សាលាឧទ្ធរណ៍អាចចេញសាលដីកាកំបាំងមុខ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីអវត្តមាន ឬមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីនេះ[54] ។ ដើមបណ្តឹងឧទ្ធរណ៍អាចតវ៉ាលើសាលដីកាដែលចេញពេលខ្លួនអវត្តមាន តាមរយៈការរៀបចំពាក្យបណ្តឹងជំទាស់ដែលជាថ្មីម្តងទៀតត្រូវប្រើប្រាស់នីតិវិធី និងរយៈពេលកំណត់ដូចនៅតុលាការ ជាន់ទាបដែរ ។ ប្រសិនបើភាគីដែលប្តឹងជំទាស់មិនមកបង្ហាញខ្លួនជាលើកទីពីរ សាលាឧទ្ធរណ៍នឹងចេញសាលដីកាកំបាំងមុខ ជាលើកទីពីរហើយចាត់ទុកជាចំពោះមុខ សាលដីការនេះអាចជជែកតវ៉ាបាន តែតាមរយៈបណ្តឹងសារទុក្ខ ទៅតុលាការកំពូលតែប៉ុណ្ណោះ ។

### ៣.៣ សិទ្ធិធ្វើបណ្តឹងសារទុក្ខ

គឺជាការធ្វើបណ្តឹងតវ៉ា ឬបដិសេធសេចក្តីសម្រេច ឬសាលដីការបស់សាលាឧទ្ធរណ៍ ។ ពោលគឺនៅពេលដែលភាគីកើតទុក្ខមិនសុខចិត្តហើយត្រូវបើកឱ្យគូក្តីប្តឹងទៅសាលាជំនុំជម្រះក្តីជាន់ខ្ពស់ ឬ តុលាការកំពូល[55]។

តុលាការកំពូលមានទីតាំងស្ថិតនៅទីក្រុងភ្នំពេញ ដែលជាតុលាការធំជាងគេនៅទូទាំង ប្រទេសហើយមានសមត្ថកិច្ចអនុវត្តទូទាំងប្រទេសទាំងមូល ។ តុលាការកំពូលគឺជាតុលាការដែលដោះស្រាយចុងក្រោយបំផុតទទួល ពាក្យបណ្តឹងសាទុក្ខ ដែលមិនសុខចិត្តនឹងសាលដីកាសាលាឧទ្ធរណ៍ ។ បណ្តឹងសាទុក្ខមានអានុភាពផ្អាកការអនុវត្តន៍ សាលដីការបស់សាលាឧទ្ធរណ៍រហូតដល់មានប្រកាសសាលដីការបស់តុលាការកំពូល[56] ។ ក្រៅពីមានការ លើកលែងបន្តិចបន្តួច តុលាការកំពូលអាចកាត់សេចក្តីតែលើអង្គច្បាប់ប៉ុណ្ណោះ ។

---

[52] មាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[53] មាត្រា ៤០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[54] មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[55] វចនានុក្រម លោក ហ៊ឹង ធីឫទ្ធិ ឆ្នាំ ២០១៤

[56] មាត្រា ៤៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ការប្តឹងសាទុក្ខទៅតុលាការកំពូល ចេញជាលទ្ធផលក្នុងការផ្ទេរសមត្ថកិច្ច ពិនិត្យឡើងវិញអំពីអង្គច្បាប់ទាំងអស់នៅក្នុងសាលដីកាសាលាឧទ្ធរណ៍ ប្រសិនបើភាគីប្តឹងសារទុក្ខ មិនបានបង្ហាញនូវបញ្ហាជាក់លាក់នោះទេ ។

ក្នុងករណីដែលភាគីប្តឹងសារទុក្ខបានបង្ហាញបញ្ហា ជាកំណត់ណាមួយនៅក្នុងបណ្តឹងសាទុក្ខ នោះតុលាការកំពូលត្រូវជំនុំជម្រះតែទៅលើបញ្ហាដែលប្តឹងនោះតែប៉ុណ្ណោះ ។

តុលាការកំពូលត្រូវសម្រេចចេញសាលដីការបស់ខ្លួនទាំងលើបញ្ហាអង្គហេតុ និងអង្គច្បាប់តាម រយៈការបង្កើតឡើងក្រុមប្រឹក្សាជំនុំជម្រះរួមក្រុម ។ ក្រុមប្រឹក្សានេះរួមមានចៅក្រម ៩រូប មកពីផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌក្នុងតុលាការកំពូល ។

បណ្តឹងសាទុក្ខគឺធ្វើក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃប្រកាសាលក្រម ឬសាលដីកា[57] ។អ្នកដែលអាចធ្វើបណ្តឹងសាទុក្ខបានមានដូចជា ភាគី ឬតំណាងរបស់ភាគីដែលបានទទួលសិទ្ធិ ដូចជាមេធាវីការពារក្តី និង ឪពុកម្តាយ ឬ អាណាព្យាបាលរបស់អនីតិជន ។

បណ្តឹងសាទុក្ខត្រូវចុះក្នុងបញ្ជី របស់ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលជាអ្នករៀបចំសំណុំរឿងនិងបញ្ជូនសំណុំរឿងនោះទៅតុលាការកំពូល[58] ។ ពាក្យបណ្តឹងសាទុក្ខត្រូវចុះហត្ថលេខាឬផ្តិតមេដៃព្រមទាំងចុះហត្ថលេខាដោយក្រឡាបញ្ជីរបស់សាលាឧទ្ធរណ៍ និងចុះកាលបរិច្ឆេទ (ដោយផ្អែកលើកាលបរិច្ឆេទ នៃការទទួលពាក្យបណ្តឹងសាទុក្ខ)[59] ។

ដើមបណ្តឹងសាទុក្ខត្រូវដាក់សារណាដល់តុលាការក្នុងអំឡុងពេល ២០ថ្ងៃ ។រយៈពេលនេះអាចបន្តបាន ១០ថ្ងៃ (មាត្រា ៤២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) បន្ថែមទៀតប្រសិនបើ ដើមបណ្តឹងសាទុក្ខជាអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍គាត់ត្រូវភ្ជាប់ជូននូវសេចក្តីសន្និដ្ឋាន ដែលបង្ហាញអំពីបញ្ហាអង្គច្បាប់នៅក្នុងរឿងក្តីទៅឱ្យតុលាការកំពូល ។ នៅពេលសារណារបស់ដើមបណ្តឹងសាទុក្ខដាក់ជូនទៅតុលាការកំពូល ក្រឡាបញ្ជីត្រូវបញ្ជូនសារណានេះមួយច្បាប់ទៅឱ្យគូភាគី (ឬតំណាងរបស់គេ) ដើម្បីរៀបចំឆ្លើយតបមកវិញ ។ អ្នកដែលត្រូវឆ្លើយតបមានពេល ២០ថ្ងៃ ដើម្បីដាក់សារណាតបរបស់ខ្លួនជូនមកតុលាការ ដែលដូចគ្នានេះដែរអាចបន្តបន្ថែមបាន ១០ថ្ងៃទៀតតាមសំណើរ ។ ប្រសិនបើពុំគោរពតាមទំរង់ខាងលើ ដំណើការបណ្តឹងឧទ្ធរណ៍ត្រូវចាត់ទុកជា

[57] មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[58]មាត្រា ៤២៤ និង ៤២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[59] មាត្រា ៤២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

មោឃៈ ។ ភាគីដែលខូចប្រយោជន៍ ដោយសារការពុំគោរពតាមទំរង់ការ នេះអាចស្នើសុំឱ្យ តុលាការចាប់ផ្តើមសវនាការសារជាថ្មីពីចំនុចដែលដំណើរការនេះត្រូវបានរារាំង និងមានភាពមិនប្រក្រតី ។ ទោះបីជាភាគីទាំងពីរមិនបានដាក់សារណារបស់ខ្លួនតាមពេលកំណត់ ប្រធានតុលាការកំពូលនៅ តែត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមដែលរៀបចំរបាយការណ៍ដោយមិនចាំបាច់មានសារណា ។ តាមច្បាប់សវនាការត្រូវធ្វើឡើងក្នុងរយៈពេល ៣ខែ បន្ទាប់ពីបានទទួលសំណុំរឿងពេញលេញរួចហើយ ។

ដំណើរការសវនាការរបស់តុលាការកំពូល និងបទវិន័យបន្ទប់សវនាការគឺដូចគ្នានិងតុលាការ ថ្នាក់ក្រោមដែរ ។ ក្រុមប្រឹក្សាជំនុំជម្រះបើក សវនាការដោយមានសមាសភាពចៅក្រម ៥រូប ក្នុងនោះមានប្រធានតុលាការកំពូលដែលត្រូវធ្វើជាប្រធាន ។ សវនាការរបស់តុលាការកំពូលគឺត្រូវធ្វើជាសាធារណៈ ហើយសាលដីកាក៏ត្រូវប្រកាសជាសាធារណៈដែរ តុលាការកំពូលមិនអាចពិចារណា ឬចេញសាលដីកាលើបណ្តឹងសាទុក្ខណាមួយដែលមិនបានបើកសវនាការជាសាធារណៈនោះឡើយ ។ ភាគីទាំងអស់អាចតំណាង ឬការពារដោយមេធាវីរបស់គេ ។

នៅពេលចាប់ផ្តើមសវនាការ ចៅក្រមត្រូវអានរបាយករណ៍ជាសាធារណៈ ។ បន្ទាប់មកតំណាងអយ្យការ លើកឡើងនូវសំអាងរបស់ខ្លួន ហើយបន្ទាប់មកដើមបណ្តឹងសាទុក្ខ ចុងបណ្តឹងសាទុក្ខ និងមេធាវីដែលការពារឱ្យភាគីនីមួយៗ ។ សិទ្ធិក្នុងការឆ្លើយតបត្រូវតែគោរពឱ្យបាន។ នៅចុងបញ្ចប់នៃការជជែកដេញដោល ក្រុមប្រឹក្សាជំនុំជម្រះថយទៅពិចារណាដើម្បីសម្រេចសេចក្តីរបស់ខ្លួន ។ ភាគីនីមួយៗអាចដាក់ជូនផ្លូវសំអាងថ្មី ឬចំណុចច្បាប់ ថ្មីឱ្យទៅសវនាការពិនិត្យរហូតដល់ការសួរដេញដោលត្រូវបានប្រកាសបិទជាសាធារណៈ ។

សាលដីការបស់តុលាការកំពូល គឺត្រូវសម្រេចដោយផ្អែកលើចំនួនភាគច្រើន ហើយត្រូវអានភ្លាម បន្ទាប់ពីការពិចារណា ឬក៏អាចប្រកាសនៅពេលក្រោយតាមកាលបរិច្ឆេទកំណត់ដោយតុលាការ ។

ប្រសិនបើតុលាការកំពូលឯកភាពជាមួយនឹងសាលដីការបស់សាលាឧទ្ធរណ៍ សាលដីកានេះត្រូវមានអានុភាពអនុវត្តភ្លាម ។

ប្រសិនបើតុលាការកំពូលមិនឯកភាពជាមួយនិងសាលដីកា របស់សាលាឧទ្ធរណ៍ សាលដីការបស់សាលាឧទ្ធរណ៍អាចត្រូវបានធ្វើការកែតម្រូវ ឬបដិសេធ ហើយតុលាការកំពូលនឹងណែនាំសាលាឧទ្ធរណ៍ឱ្យចាត់វិធានការសមស្របតាមការណែនាំដូចមានចែងក្នុងសាលដីកា ។ នៅពេលដែលមានការបដិសេធទាំងស្រុង សាលាឧទ្ធរណ៍ ត្រូវរៀបចំសវនាការជាលើកទីពីរ ដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានសមាសភាពចៅក្រមថ្មី ៣ រូប ។

ប្រសិនបើនៅសវនាការលើកទី២នេះ សាលាឧទ្ធរណ៍នៅតែមិនឯកភាព ជាមួយនឹងសេចក្តីសម្រេចរបស់តុលាការកំពូល ហើយមានបណ្តឹងសាទុក្ខលើកឡើងប្រឆាំង និងសាលដីកាទី២របស់សាលាឧទ្ធរណ៍ តុលាការកំពូល និងទទួលខុសត្រូវលើរឿងក្តីទាំងមូល ហើយរៀបចំដំណើរការថ្មី បើកសវនាការពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ។ សវនាការត្រូវធ្វើឡើងដោយរួមក្រុមដែលមានសមាសភាពសម្រេចលើបណ្តឹងសាទុក្ខ៩រូប ឬសមាសភាពជំនុំជម្រះជាសភាពេញអង្គ( ក្នុងករណីបណ្តឹងសាទុក្ខលើកទី២ ) យ៉ាងតិច ៩រូប ឬ ក៏អាចលើសពី ៩រូបក៏បានផងដែរ[60] ប៉ុន្តែបើយោងតាមការអនុវត្តជាក់ស្តែង គឺមានតែ៩ រូបប៉ុណ្ណោះ។

[60] មាត្រា ៦២ ច្បាប់ស្តីពីការរៀបចំអង្គតុលាការ

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការពិភាក្សាបកស្រាយខាងលើយើងឃើញថា សិទ្ធិជនជាប់ចោទគឺជាសិទ្ធិមួយដ៏សំខាន់និងចាំបាច់ បំផុតសម្រាប់ជនជាប់ចោទក៏ដូចជាសំរាប់មនុស្ស ឬពលរដ្ឋគ្រប់រូប។ សិទ្ធិជនជាប់ចោទគឺជាសិទ្ធិរបស់ពលរដ្ឋព្រោះថា ជនជាប់ចោទគេចាត់ទុកថាជាជនគ្មានទោសកំហុសរហូតដល់មានសាលក្រម ឬសាលដីកាស្ថាពរ តាមគោលការណ៍ សន្មត់ជាមុនថាគ្មានទោស) ។ ហេតុនេះហើយជនដែលត្រូវបានគេចោទប្រកាន់នោះត្រូវតែមាននិងត្រូវតែទទួលបាន នូវសិទ្ធិរបស់ខ្លួនទាំងឡាយនេះដើម្បីការពារខ្លួន ដើម្បីបញ្ជាក់នូវភាពស្មោះត្រង់របស់ខ្លួននិងដើម្បីអោយជនជាប់ ចោទអាចទទួលបាននូវភាពយុត្តិធម៌ពីតុលាការមួយដែលមានឯករាជ្យ។

សិទ្ធិរបស់ជនជាប់ចោទនេះ គឺមិនមែនត្រឹមទទួលបានតែនៅក្នុងពេលសវនាការនោះទេ គឺត្រូវទទួលបានគ្រប់ ដំណាក់កាលនៃនីតិវិធីក្នុងដំណើរការរាប់ចាប់តាំងពីពេលចាប់ខ្លួនរហូតដល់មានសាលក្រម ឬសាលដីកាសម្រេចជា ស្ថាពរថាត្រូវលើកលែងការចោទប្រកាន់ សម្រេចចអោយរួចខ្លួន ឬក៏ត្រូវមានទោសក្លាយជាទណ្ឌិត ។ករណីនេះមិនមែន មានន័យថា ពេលមានសាលក្រម ឬសាលដីកាស្ថាពរហើយនោះជនជាប់ចោទមិនបានទទួលនូវសិទ្ធិនេះនោះទេ គឺគ ទទួលបាននូវសិទ្ធិសេរីភាពពេញលេញដូចពលរដ្ឋធម្មតា ឬក៏ក្លាយជាទណ្ឌិតដែលត្រូវអនុវត្តទោសនៅក្នុងពន្ធនាគារ ពោលគឺគេបានរួចផុតពីពាក្យថា ជនជាប់ចោទ។

នៅក្នុងប្រទេសកម្ពុជា យើងសង្កេតឃើញថារដ្ឋាភិបាលយើងមានការយកចិត្តទុកដាក់គិតគូរដល់សិទ្ធិពលរដ្ឋយ៉ាងខ្លាំងក្លាផងដែរ ពោលគឺរដ្ឋាភិបាលបានពិភាក្សាល្អិតល្អន់ពីសំណាក់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ពីសភាធម្មនុញ្ញ មុនពេលចងក្រងនូវរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ។ រដ្ឋធម្មនុញ្ញនេះគឺមានចែងអំពីសិទ្ធិទាក់ទងនិងជនជាប់ចោទព្រមទាំង បានចែងទទួលស្គាល់ជាចំហរនៅក្នុងលិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិយ៉ាងទូលំទូលាយទៀតផង ។ ជាងនេះទៅ ទៀត សិទ្ធិនេះត្រូវបានគេចែងបញ្ចូលនៅក្នុងច្បាប់ព្រហ្មទណ្ឌថែមទៀតផងដែរ ដូចជា ក្រមព្រហ្មទណ្ឌអន្តរកាលឆ្នាំ២០០៩ និងក្នុងក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌ ២០០៧ជាច្រើនមាត្រា ដែលច្បាប់ទាំងអស់នេះយើងបានយក មកអនុវត្តរហូតមកដល់ពេលបច្ចុប្បន្ន។ ។ ថ្វីត្បិតតែច្បាប់ទាំងអស់នេះវាបានកើតមុនរដ្ឋធម្មនុញ្ញក៏ដោយ តែច្បាប់ ទាំងអស់នេះបាននៅស្របជាមួយរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋ។

ម្យ៉ាងវិញទៀតយើងសង្កេតឃើញថា រាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សនេះយ៉ាងខ្លាំងដូចតាមរយះការសហការ បើកអោយមានយ៉ាងទូលំទូលាយនូវអង្គការក្រៅរដ្ឋាភិបាលនានា ជាពិសេសគឺអង្គការដែលមានបេសកម្មបំពីដល់ផ្នែកសិទ្ធិមនុស្ស និងមានការិយាល័យមេធាវីជាច្រើននៅតាមបណ្តាខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជាយើង ។ ទាំងអស់នេះគឺក្នុងគោលបំណងជួយពង្រឹងការគោរសិទ្ធិមនុស្សអោយបានរឹងមាំ ព្រោះថាព្រះរាជាណាចក្រកម្ពុជាយើងជាប្រទេសតូចមួយដែលទើបរួចផុតពីសង្គ្រាម និងជាប្រទេសដែលទើបតែងាកមកកាន់នូវរបបលទ្ធិប្រជាធិបតេយ្យ ពោលគឺជាប្រទេសប្រជាធិបតេយ្យមួយដ៏ក្មេងខ្ចី ។

តែផ្ទុយមកវិញអ្វីដែលមានការសោកស្តាយ និងខំប្រឹងប្រែងតទៅទៀតនោះ នៅប្រទេសកម្ពុជាយើងសព្វថ្ងៃ នៅមិនទាន់មានការគោរពសិទ្ធិមនុស្សបានគ្រប់គ្រាន់នៅឡើយនោះទេ។ ជាក់ស្តែងដូចតាមរយៈសារពត៌មាន ដែលបានចុះផ្សាយស្ទើរតែរាល់ថ្ងៃអំពីការប្រើអំពើហឹង្សាផ្សេងៗ ពីសំណាក់មន្ត្រីអនុវត្តច្បាប់មួយចំនួនដែលបានវាយដំបង្ខំលើរូបរាងកាយក្នុងការសួរចំលើយដល់ជនសង្ស័យ ឬជនជាប់ចោទ។ មិនតែប៉ុណ្ណោះមានការបើកដៃ ពីមន្ត្រីប្រភេទនេះអោយដល់ហ្វូងមហាជនសំលាប់ជនសង្ស័យដោយគ្មានការហាមឃាត់ ឬតាមចាប់ក្រុមជនដៃដល់មកផ្តន្ទទោសតាមច្បាប់នោះឡើយ។ នេះគឺជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរណាស់ព្រោះថានៅក្នុងប្រទេសកម្ពុជា យើងពុំ មានទោសប្រហារជីវិតនោះទេ ទោះបីតុលាការរកឃើញថាជនសង្ស័យនោះមានទោសពិតមែន ក៏មិនត្រូវស្លាប់ដែរ គឺកំរិតទោសអតិបរមាត្រឹមជាប់ពន្ធនាគារអស់មួយជីវិតប៉ុណ្ណោះ ។

ដូច្នេះចំពោះចំនុចទាំងអស់ដែលបានលើកឡើងខាងលើនេះ រដ្ឋាភិបាលគួរតែពង្រឹងឡើងវិញនូវការអនុវត្តន៍ច្បាប់អោយមានប្រសិទ្ធិភាពខ្ពស់ ពង្រឹងនូវការគោរពសិទ្ធិមនុស្ស ព្រមទាំងចាត់វិធានការដ៏តឹងរ៉ឹងមួយក្នុងការ ផ្តន្ទាទោសចំពោះបុគ្គលណាដែលប្រើអំណាចគាបសង្កត់ ជាហេតុនាំអោយមានការរំលោភសិទ្ធិមនុស្សជាពិសេសគឺ ចំពោះជនជាប់ចោទតែម្តង ។ បើធ្វើដូច្នេះបានយើងសង្ឃឹមយ៉ាងមុតមាំថា ប្រជាពលរដ្ឋខ្មែរយើងពិតជារស់នៅប្រកបទៅដោយសេចក្តីសុខព្រោះថាយើងបានរស់នៅក្នុងប្រទេសមួយដែលមានច្បាប់ទំលាប់ និងការគោរពច្បាប់បាន ល្អជាពិសេសទៅទៀតនោះប្រទេសយើងនឹងក្លាយជានីតិរដ្ឋ ដែលជាបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលយូរយារណាស់មកហើយ ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សា ស្រាវជ្រាវទៅលើប្រធានបទសិទ្ធិជនជាប់ចោទនៅកម្ពុជា ទោះបីជាមានការ លំបាកបន្តិចក៏ដោយតែវាក៏បានធ្វើអោយយើងខ្ញុំដែលជាអ្នកស្រាវជ្រាវ បានយល់ដឹងកាន់តែច្បាស់ពីសិទ្ធិ ទាំងឡាយដែលនិងត្រូវយកមកអនុវត្តចំពោះជនជាប់ចោទ និងបានផ្តល់នូវចំណេះដឹងជាច្រើនអំពីផ្នែកមួយ នេះព្រោះជាផ្នែកមួយដែលបានផ្សារភ្ជាប់ពីការអនុវត្តក្នុងសង្គម ស្របទៅនិងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ទៅលើសិទ្ធិជនដែលត្រូវបានជាប់ចោទ និងជាផ្នែកមួយយ៉ាងសំខាន់ ដល់ក្រុមនិស្សិតដែលកំពុងសិក្សា ផ្នែកនិតិសាស្ត្រ ក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ ពីព្រោះប្រធានបទនេះបានផ្តោតសំខាន់ទៅលើ ជនដែល ត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមដីការរបស់តុលាការ និងសិទ្ធិរបស់ពួកគេនៅពេលដែលជននោះត្រូវបាន ជាប់ចោទក្នុងករណីណាមួយដែលខុសនិងច្បាប់ ហើយផ្នែកទាំងនោះមានដូចជាការការពារសិទ្ធិជនជាប់ចោទក្នុងច្បាប់ជាតិ សិទ្ធិទទួលបានការថែទាំសុខភាព សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងជាពិសេសនៅ ពេលដែលទទួលបាននូវភាពអយុត្តិធម៌ ជនជាប់ឃុំទាំងនោះមានសិទ្ធិប្តឹងឧទ្ធរណ៍ ដោយស្របទៅតាម បញ្ញត្តិនៃច្បាប់ដែលបានចែងទុក ក្នុងគោលបំណង់ការពារការបំពានសិទ្ធណាមួយ ទៅលើជនទាំងនោះ។

ប៉ុន្តែបន្ទាប់ពីការសិក្សាស្រាវជ្រាវទាក់ទងក្នុងប្រធានបទនេះយើងឃើញថា ការអនុវត្តសិទ្ធិរបស់ ជនជាប់ចោទជាក់ស្តែងនៅកម្ពុជាមិនទាន់បានពេញលេញនោះទេ ពោលការអនុវត្តគឺមានការខ្វះចន្លោះដូចជា ការអនុវត្តផ្តល់សិទ្ធិដល់ទណ្ឌចំពោះការជួបក្រុមគ្រួសារ ឬមិត្តភក្តិការទទួលបានការព្យាបាលនៅពេល មានជម្ងឺ ការប្រើប្រាស់ថ្នាំសង្កូវដែលក្រុមគ្រួសារបានផ្ញើអោយក្នុងពេលជាប់ឃុំជាដើមដែលការអនុវត្តមិន ទាន់បានពេញលេញនៅឡើយទេ ដែលធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់។

ដូច្នេះដើម្បីទប់ស្កាត់ការរលំលោភបំពានសិទ្ធិរបស់ជនជាប់ចោទ យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវយល់ថា កម្ពុជាគួរតែមានវិធានការលើកតម្កើនសិទ្ធិជនជាប់ឃុំអោយបានល្អជាងនោះ ព្រោះដើម្បីធានាថា កម្ពុជាបានអនុវត្ត និងធានាដល់សិទ្ធិមនុស្ស គ្រប់ទីកន្លែង និងត្រូវបានការពារដោយច្បាប់របស់ជាតិ និង អន្តរជាតិ និងជួយពង្រឹងការគោពសិទ្ធិមនុស្សអោយបានរឹងមាំ ។

# ឯកសារយោង

## ឯកសារយោង


១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

៤. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

៥. ច្បាប់ព្រហ្មទណ្ឌអន្តរកាល

៦. ច្បាប់ស្តីពីពន្ធនាគារ

៧. បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងអ្នកទោស

៨. នីតិព្រហ្មទណ្ឌទូទៅ ដោយលោក រុន ពណ្ណារិទ្ធ,បោះពុម្ពឆ្នាំ២០២២

៩. អត្ថាធិប្បាយវចនានុក្រមច្បាប់ដោយលោក ហ៊ីង ធីឫទ្ធិ បោះពុម្ពលើកទី៤ ឆ្នាំ២០១៤

១០. សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ធ្នូ ១៩៤៨

១១. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៦ ធ្នូ ១៩៦៦

១២. អនុសញ្ញាអន្តរជាតិទីក្រុងរ៉ូមចុះថ្ងៃទី ១០ សីហា ១៩៩៨ ស្តីពីលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ

១៣.បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល (UNTAC, APRONUC) ចុះថ្ងៃទី ១០ កញ្ញា ១៩៩២

# ឧបសម្ព័ន្ធ

គំរូដីកាបង្គាប់ឲ្យចូលខ្លួន៖

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>សាលាដំបូងខេត្ត.............</u>**

លេខអយ្យការ: ..........................

លេខស៊ើបសួរ: ..........................

លេខ:..........................

## *<u>ដីកាបង្គាប់ឲ្យចូលខ្លួន</u>*

**យើង ..................... ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត............ ។**

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ .................... ចុះថ្ងៃទី ........... ខែ...........ឆ្នាំ ............ របស់តំណាងអយ្យការអមសាលាដំបូងខេត្ត .................... ដែលបើកការប្រឆាំងនឹងជនត្រូវចោទឈ្មោះ ...................... ពីបទ: ...................... ប្រព្រឹត្តនៅភូមិ ......... ឃុំ ......... ស្រុក ........... ខេត្ត ........... កាលពីថ្ងៃទី........ ខែ.......... ឆ្នាំ......... បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា.......... នៃច្បាប់............................... ។

## <u>បង្គាប់មក</u>

ឈ្មោះ .................. ភេទ...... អាយុ........ រស់នៅភូមិ ........ ឃុំ.........ស្រុក.........ខេត្ត....................

**<u>ឲ្យចូលមកកាន់សាលាដំបូងខេត្ត...................................</u>** ។

- **នៅថ្ងៃទី** .................. **ខែ** ............. **ឆ្នាំ** ............ **វេលាម៉ោង** ............................ ជាកំណត់ ។
- ដើម្បី ឆ្លើយបំភ្លឺពីដំណើររឿងពាក់ព័ន្ធ និងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

សាមីខ្លួនត្រូវចូលមកបង្ហាញខ្លួនឲ្យទាន់ពេលវេលា តាមការកំណត់ខាងលើ និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងសំណុំរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើទេ **<u>យើងនឹងចេញបញ្ជាឱ្យកម្លាំងសាធារណៈបង្ខំសាមីខ្លួនឱ្យចូលមកបង្ហាញខ្លួនទេ យើងចេញដីកាបង្គាប់ឱ្យនាំខ្លួន ។</u>**

ធ្វើនៅ........... ថ្ងៃទី .......... ខែ .......... ឆ្នាំ..........

**ចៅក្រមស៊ើបសួរ**

**ហត្ថលេខា និង ត្រា**

<u>គំរូកំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**

**ក្រុងភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ.......

ចុះថ្ងៃទី.....ខែ.......ឆ្នាំ២០០.. **កំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**

ឆ្នាំពីរពាន់...............ខែ............ថ្ងៃទី................វេលាម៉ោង..............។

**យើង**.....................................តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ

បានឃើញសំណុំរឿងលេខ[៨]......................ចុះថ្ងៃទី.........ខែ.........ឆ្នាំ.......

របស់...........................................................។

**បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម :**

**នាមត្រកូល**......................**នាមខ្លួន**.................................ហៅ...........

ភេទ........អាយុ.......ឆ្នាំជាតិ.................របររកស៊ី...............................

**ទីកន្លែងកំណើត**..........................ឃុំ-សង្កាត់...................................

ស្រុក-ខណ្ឌ...............................ខេត្ត-ក្រុង...............................

**ទីលំនៅបច្ចុប្បន្ន**.......................... ឃុំ-សង្កាត់...................................

ស្រុក-ខណ្ឌ.....................................ខេត្ត-ក្រុង..............................

ទោសពីមុន........ឪពុកឈ្មោះ....................."រ.ស"ម្ដាយឈ្មោះ..................."

រ.ស" ប្ដី ឬប្រពន្ធឈ្មោះ..................."រ.ស"មានកូន.........ឬនៅលីវ

**អនីតិជន☐ ឬនីតិជន☐** ។

---

[៨] **លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌**

**បើកការស៊ើបសួរលើអង្គហេតុខាងលើនិង:**

☐ **ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ**[៦] :...............................................................................................................

...............................................................................................................................................

..............................................................................................................................................។

☐ **ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**[៧] :.........................................................................

...............................................................................................................................................

..........................................................................................................................................។

☐ **ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន**[៨] :...............................................................................

...............................................................................................................................................

..............................................................................................................................................។

ធ្វើនៅអយ្យការ. ថ្ងៃទី..........ខែ.............ឆ្នាំ២០០...

**តំណាងអយ្យការ**

---

[៦] ឈ្មោះជនត្រូវចោទ

[៧] កាតព្វកិច្ចណាមួយដែលមានចែងនៅក្នុងមាត្រា ២២៣

[៨] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងមាត្រា ២០៥

គំរូដីកាបង្គាប់ឲ្យចាប់ខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត.............**

លេខអយ្យការ: ..........................

លេខស៊ើបសួរ: ..........................

លេខ: ..........................

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង ...............ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត......................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: .................. ចុះថ្ងៃទី ............ ខែ .......... ឆ្នាំ ..............។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ............. ចុះថ្ងៃទី ............. ខែ .......... ឆ្នាំ ......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត............................។

បានឃើញដីកាបញ្ជូនឲ្យឆ្លើយលេខ: .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ ............ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្ត.....................................។

**ក្រោយពីបានពិនិត្យសំណុំរឿងទប់សព្វគ្រប់**

**យល់ឃើញថា**

- .....................................................................................................................

-.....................................................................................................................

-.....................................................................................................................

## ហេតុដូច្នេះសម្រេច

១- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ឲ្យចាប់ និងនាំខ្លួនជនឈ្មោះ:.............ភេទ........ជាតិ........អាយុ.............ឆ្នាំ កើតនៅភូមិ...................ឃុំ............ស្រុក...................ខេត្ត..................... រស់នៅភូមិ...............ឃុំ................ស្រុក...................ខេត្ត...............ឪពុកឈ្មោះ: ............. ម្តាយឈ្មោះ: ................ នៅលើវមានប្រពន្ធឈ្មោះ:........................ ទោសពីមុន..............................................។

២- បង្គាប់ឲ្យប្រធានពន្ធនាគារខេត្តកំពង់ធំ ទទួលយកជននេះ រហូតដល់មានបទបញ្ជាកថ្មីសម្រេចផ្សេងពីនេះ ។

៣- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ច នៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ ត្រូវអនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់ ។

............., ថ្ងៃទី............ ខែ.......... ឆ្នាំ.............

**ចៅក្រមស៊ើបសួរ**

គំរូដីកាបង្គាប់ឲ្យនាំខ្លួនៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត.............**

លេខអយ្យការៈ .........................

លេខស៊ើបសួរៈ .........................

លេខៈ.........................

## ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទ

យើង ........................ ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត........................ ។

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦០០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ........................ ចុះថ្ងៃទី ........ ខែ ......... ឆ្នាំ .......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត ............. ដែលបើកការប្រឆាំងនឹងជនត្រូវចោទ ............................. ពីបទៈ .................. ប្រព្រឹត្តនៅភូមិ ............ សង្កាត់ ......... ក្រុង .......... ខេត្ត ............ កាលពីថ្ងៃទី .......... ខែ ....... ឆ្នាំ .......... តាមបញ្ញត្តិមាត្រា ............ នៃច្បាប់........................................................ ។

យល់ឃើញថា ........................................................................................................ ។

យល់ឃើញថា ........................................................................................................ ។

យល់ឃើញថា ........................................................................................................ ។

**ហេតុដូច្នេះសម្រេច**

- បង្គាប់ឲ្យនាំខ្លួនឈ្មោះ ...................... ភេទ......... អាយុ.......ឆ្នាំ កើតនៅថ្ងៃទី .... ខែ .... ឆ្នាំ ........ មានទីកន្លែងកំណើតនៅភូមិ...............ឃុំ.............ស្រុក...............ខេត្ត.............. និងរស់នៅបច្ចុប្បន្ននៅភូមិ............... ឃុំ.............ស្រុក...............ខេត្ត.............. ឪពុកឈ្មោះ .................. ម្ដាយឈ្មោះ ................. មកកាន់សាលាដំបូងខេត្ត....................... ដើម្បីសាកសួរយកព័ត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

- បង្គាប់មក **ភ្នាក់ងារមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់** អនុវត្តដីកានេះឲ្យបានសម្រេច ។

.................., ថ្ងៃទី............ខែ .......... ឆ្នាំ ..............

**ចៅក្រមស៊ើបសួរ**

**ហត្ថលេខា និង ត្រា**

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.....................................................................។

ជាបទល្មើស.............................................................................................................

...............ប្រព្រឹត្តនៅ.....................................................................................................

..................................កាលពីថ្ងៃទី........ខែ.........ឆ្នាំ២០០....ដែលចែងក្នុងមាត្រា.............

នៃច្បាប់.................................................................................................................។

**សវនាការនេះនឹងប្រព្រឹត្តទៅនាថ្ងៃទី.......ខែ.......ឆ្នាំ.........វេលាម៉ោង............នៅ.........**

**................................................។**

សាមីខ្លួនអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

សាមីខ្លួនត្រូវចូលបង្ហាញខ្លួនឱ្យទាន់ពេលវេលា នឹងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅអយ្យការ, ថ្ងៃទី........ខែ.........ឆ្នាំ២០០....

**តំណាងអយ្យការ**

យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ

:.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.................................................................................... ។

**អង្គហេតុនេះជាបទល្មើស**........................................................................

......ប្រព្រឹត្តនៅ..........................................................................................

កាលពីថ្ងៃទី.........ខែ..........ឆ្នាំ២០០.....ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា................

......នៃច្បាប់...................................................................................... ។

**យើងបានទទួលចម្លើយពីជននេះដូចតទៅ:**.........................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................។

**យើងបានប្រាប់ដល់ជននេះថា** : ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឱ្យ មានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

**ជននេះបានឆ្លើយថា** :

☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី .............................. ។

☐ ខ្ញុំសូមស្នើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ។

**យើងបានបញ្ជាក់ថា** :

☐ លោក/លោកស្រីមេធាវី..............................អាចពិនិត្យសំណុំរឿងនិងទាក់ទង ជាមួយ ជនជាប់ចោទ ។

☐ យោងលើសំណើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតំណាង គណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

☐ លោក/លោកស្រីមេធាវី..............................អវត្តមាន ។

បានឃើញមាត្រា **៤៧** មាត្រា **៤៨** និងមាត្រា **៣០៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

**បញ្ជូនជនជាប់ចោទឈ្មោះ**.................................................................. ......ទៅតុលាការដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសដូច ខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង ។

**ជនជាប់ចោទ** **តំណាងអយ្យការ**

<u>គំរូដីកាកោះហៅថាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ (ទី ២)</u>

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**

**ក្រុងភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ.......

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ចុះថ្ងៃទី.....ខែ**ឃើញ**.......ឆ្នាំ២០០:::..........................តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ។

**បញ្ជាឱ្យចូលទៅបង្ហាញខ្លួននៅសវនាការ :**

**នាមត្រកូល**.....................**នាមខ្លួន**................................ហៅ..............

ភេទ........អាយុ.......ឆ្នាំ ជាតិ................របររកស៊ី..................................

**ទីកន្លែងកំណើត**................................ឃុំ-សង្កាត់..............................

ស្រុក-ខណ្ឌ....................................ខេត្ត-ក្រុង..................................

**ទីលំនៅបច្ចុប្បន្ន**.............................ឃុំ-សង្កាត់..................................

ស្រុក-ខណ្ឌ....................................ខេត្ត-ក្រុង..................................

ទោសពីមុន........ឪពុកឈ្មោះ..................."រ.ស" ម្ដាយឈ្មោះ..................."រ.ស"

ប្ដី ឬប្រពន្ធឈ្មោះ.................."រ.ស" មានកូន.........ឬនៅលីវ **អនីតិជន**☐ ឬ**នីតិជន**☐ ។

**ជនត្រូវបានចោទប្រកាន់ពី(អង្គហេតុ[១]):**.......................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

[១] សេចក្ដីសង្ខេបអង្គហេតុដែលភ្ជាប់ពីធាតុសត្យានុម័ត និងអត្តនោម័ត

# ឧបសម្ព័ន្ធ ទី២

# កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យចូលជាសមាជិក
តាមសេចក្តីសម្រេចចិត្តលេខ២២០០A (XXI)
ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ
ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ស្របតាមមាត្រា៤៩

## បុព្វកថា

*រដ្ឋភាគីនៃកតិកាសញ្ញានេះ*

*ដោយពិចារណាថា* ស្របតាមគោលការណ៍នានា ដែលបានប្រកាសនៅក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត សិទ្ធិស្មើភាពគ្នា និងសិទ្ធិដែលមិនអាចលក់ដូរ ផ្ទេរ ឬកហូតបាន របស់សមាជិកគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ទទួលស្គាល់ថា* សិទ្ធិទាំងនេះ កើតមកពីសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស ។

*ទទួលស្គាល់ថា* ស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឧត្តមគតិរបស់មនុស្សសេរី ដែលអាស្រ័យផលសេរីភាពពលរដ្ឋ និងនយោបាយ និងភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព អាចសម្រេចជោគជ័យទៅបាន លុះត្រាតែបង្កើតបានលក្ខខណ្ឌដែលឱ្យមនុស្សម្នាក់ៗ អាចប្រើប្រាស់បាននូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួន ។

*ដោយពិចារណាថា* ធម្មនុញ្ញសហប្រជាជាតិ តម្រូវឱ្យរដ្ឋនានាកាតព្វកិច្ចជំរុញឱ្យមានការគោរពជាសកល និងការអនុវត្តន៍នូវសិទ្ធិ និងសេរីភាពរបស់មនុស្ស ។

## មាត្រា ១៣

ជនបរទេស ឋិតនៅដោយស្របច្បាប់ លើដែនដីរដ្ឋភាគីនៃកតិកាសញ្ញានេះ នឹងអាចត្រូវបានបណ្តេញចេញពីរដ្ឋនោះបាន លុះត្រាតែធ្វើឡើង ដោយអនុលោមតាម សេចក្តីសម្រេចស្របតាមច្បាប់ លើកលែងតែការបណ្តេញចេញ ដោយហេតុផលបង្ខំ សម្រាប់រក្សាសន្តិសុខជាតិ ហើយជនបរទេសនេះ ត្រូវបានអនុញ្ញាតឱ្យដាក់ហេតុផល ជំទាស់នឹងការបណ្តេញចេញនេះ និងសុំឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬមនុស្សម្នាក់ ឬ ច្រើននាក់ ដែលអាជ្ញាធរបានតែងតាំងជាពិសេស ពិនិត្យករណីរបស់ខ្លួនឡើងវិញ រួម ទាំងឱ្យមានអ្នកការពារសិទ្ធិផងដែរ ។

## មាត្រា ១៤

១. ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី ។ ជនគ្រប់រូប ត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែល បង្កើតឡើងដោយច្បាប់ ជំនុំជំរះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី ។ សារព័ត៌មាន និងសាធារណៈជន អាចមិន ឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ សម្រាប់ផលប្រយោជន៍នៃទំនៀមទំលាប់ ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេល ផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់ បំផុត តាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេស ដែលថាការធ្វើជា សាធារណៈ នឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌ ។ ប៉ុន្តែ ការចេញសាលក្រម ទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែង តែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណា ព្យាបាលរបស់កុមារ ។

២. ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មត់ជាមុនថា ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់ ។

៣. ក្នុងការសម្រេចសេចក្ដី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូប មានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម ៖

(ក) ត្រូវបានពត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ ។

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង ។

(គ) ត្រូវបានជំនុំជំរះដោយឥតពន្យារពេលហួសហេតុ ។

(ឃ) ត្រូវបានជំនុំជំរះដោយមានវត្តមានរបស់ខ្លួននិងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ ។

(ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក ។

(ច) ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ ។

(ឆ) មិនត្រូវបានបង្ខិតបង្ខំ ឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ ។

៤. នីតិវិធីអនុវត្តចំពោះយុវជន-យុវនារី ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ ។

៥. ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្ដីជាន់ខ្ពស់ ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្ដន្ទាទោសឡើងវិញ ស្របតាមច្បាប់ ។

៦. នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមក ការប្រកាសឱ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោស ដោយហេតុថា អង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់តុលាការ ជនដែលទទួលរងគ្រោះ ដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់បង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេល បណ្ដាលមកពីជននោះទាំងស្រុង ឬមួយផ្នែក ។

៧. គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្ដន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើស ដែលបានផ្ដន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ របស់រដ្ឋនីមួយៗរួចហើយ ។

## មាត្រា ១៥

១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោស ដែលអនុវត្ត ក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ ។ ប្រសិនបើ

**មាត្រា ១២៩.- ថ្មី ( មាត្រា ១១០ ចាស់ )**

*ការជំរះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។*

*មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្ដី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។*

**មាត្រា ១៣០.- ថ្មី ( មាត្រា ១១១ ចាស់ )**

*គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។*



**មាត្រា ១៣១.- ថ្មី ( មាត្រា ១១២ ចាស់ )**

*មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។*

**មាត្រា ១៣២.- ថ្មី ( មាត្រា ១១៣ ចាស់ )**

*ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។*

**មាត្រា ១៣៣.- ថ្មី ( មាត្រា ១១៤ ចាស់ )**

*ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រម ដែលបានប្រព្រឹត្តខុស ។*

**មាត្រា ១៣៤.- ថ្មី ( មាត្រា ១១៥ ចាស់ )**

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និងមុខងារ។*

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតី នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមនេះ ។*

*ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្ដីស្នើថ្វាយ ព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្ដីទាំងអស់ ។*

**មាត្រា ៣៨.-**

ច្បាប់ហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបកាយបុគ្គល ណាមួយឡើយ ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយ



ក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋរបស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវ